www.kosha.or.kr
2014 – 교육미디어 –512

CAMBODIA

현장 작업자를 위한

# 산업안전보건법

# ច្បាប់សុវត្ថិភាពនិងសុខភាព

## សម្រាប់អ្នកធ្វើការផ្ទាល់នៅទីកន្លែង



산업재해예방
안전보건공단
KOREA OCCUPATIONAL SAFETY & HEALTH AGENCY

KOREA OCCUPATIONAL SAFETY & HEALTH AGENCY

이 자료는 사업장의 사업주, 안전보건관리 책임자, 안전관리자, 보건관리자 등 안전보건 관계자가 근로자를 대상으로 실시하는 안전보건교육 교재로 활용할 수 있도록 개발하였습니다. 교재파일은 안전보건공단 홈페이지 (www.kosha.or.kr) - 정보마당- 미디어뱅크 WiSH - 외국인 자료 에서 내려받아 활용하실 수 있습니다.

KOSHA

KOREA OCCUPATIONAL SAFETY & HEALTH AGENCY

ឯកសារនេះត្រូវបានចងក្រងឡើងដើម្បីឲ្យអ្នកដែលពាក់ព័ន្ធកិច្ចសុវត្ថិភាពនិងសុខភាពដូចជា ម្ចាស់អាជីវកម្ម អ្នកទទួលបន្ទុកការគ្រប់គ្រងសុវត្ថិភាព និងសុខភាព អ្នកគ្រប់គ្រងសុវត្ថិភាព អ្នកគ្រប់គ្រងសុខភាព យកធ្វើជាឯកសារអប់រំអំពីសុវត្ថិភាព និងសុខភាពដល់និយោជិក ។ ហើយយើងបានចងក្រងគម្រោងបង្រៀន ដោយផ្អែកលើសៀវភៅនេះ ដូចនេះយើងសង្ឃឹមថាលោកអ្នកនឹងប្រើប្រាស់យ៉ាងទូលាយក្នុងការអប់រំអំពីសុវត្ថិភាពនិងសុខភាព ។ អ្នកអាចចូលទាញយកគម្រោងបង្រៀននៅគេហទំព័រនៃសាជីវកម្មសាធារណៈ ដើម្បីសុវត្ថិភាពនិងសុខភាព(www.kosha.or.kr) -ទីលានព័ត៌មាន-មីឌាប៊ែង (Media bank) WiSH-ពលករអន្តោប្រវេសន៍ ។

# contents

**01 산업안전보건법 일반**

산업안전보건법 목적 ········ 08
산업안전보건법 법령체계 ········ 10

**02 산업안전보건 각 주체들의 역할과 의무**

사업주의 의무 ········ 14
근로자의 의무 ········ 34
정부의 책무 ········ 36

**03 작업장 안전보건 조치사항**

안전조치 ········ 44
보건조치 ········ 48
작업 중지 ········ 50
안전보건 표지 ········ 52

**집필자** | 강순기 (안전보건공단) **기 획** | 안전보건공단 교육미디어실 **발행일** | 초판 2014. 9 **발행인** | 백헌기
**발행처** | 안전보건공단 울산광역시 중구 종가로 400 TEL 052.7030.500 FAX 052.703.0322
**편집디자인** | 스톰커뮤니케이션 TEL 032.614.1245 **고객불편신고센터** | Tel 1644 4544 Fax 1644 4549
이 교재를 안전보건공단의 허락 없이 부분 또는 전부를 복사, 복제, 전재하는 것은 저작권법에 저촉됩니다.

# contents


## ០១ ចំនុចទូទៅនៃច្បាប់សុវត្ថិភាព និងសុខភាពក្នុងការងារ

គោលបំណងនៃច្បាប់សុវត្ថិភាព និងសុខភាពក្នុងការងារ ...................... 09

ប្រព័ន្ធច្បាប់នៃច្បាប់សុវត្ថិភាព និងសុខភាពក្នុងការងារ ...................... 11

## ០២ តួនាទី និងកាតព្វកិច្ចនៃភាគីនីមួយៗ ចំពោះសុវត្ថិភាព និងសុខភាពក្នុងការងារ

កាតព្វកិច្ចរបស់ម្ចាស់អាជីវកម្ម ................ 15

កាតព្វកិច្ចរបស់អ្នកធ្វើការ ...................... 35

កាតព្វកិច្ចរបស់រដ្ឋាភិបាល ...................... 37

## ០៣ វិធានការសម្រាប់សុវត្ថិភាព និងសុខភាពនៅកន្លែងការងារ

វិធានការសុវត្ថិភាព ................................ 45

វិធានការសុខភាព ................................ 49

ការផ្អាកការងារ ................................ 51

សញ្ញាសុវត្ថិភាពនិងសុខភាព ................ 53


---


**អ្នកនិពន្ធ** ၊ កាងស៊ូនគី (សាជីវកម្មសាធារណៈដើម្បីសុខភាពនិងសុវត្ថិភាព)
**គម្រោង** ၊ កាលបរិច្ឆេទនៅក្នុងបន្ទប់ប្រព័ន្ធផ្សព្វផ្សាយការអប់រំនៃ សាជីវកម្មសាធារណៈដើម្បីសុខភាពនិង
សុវត្ថិភាព ၊ ការបោះពុម្ពលើកដំបូង ខែកញ្ញា ឆ្នាំ ២០១៤ **អ្នកបោះពុម្ពផ្សាយ** ၊ ប៉ែកហានគី
**គ្រឹះស្ថានបោះពុម្ពផ្សាយ** ၊ សាជីវកម្មសាធារណៈដើម្បីសុខភាពនិងសុវត្ថិភាព (ប៊ូកចង់ដុង) ៩០០ ចុងកាវ៉ូ ជុងគុ ក្រុងអ៊ុលសាន ទូរស័ព្ទ ០៥២ ៧០៣០ ៥០០
ទូរសារ ០៥២ ៧០៣ ០៣២២ **អ្នករចនា** ၊ ស្លូមខមម៉្វូនីខេស្សន់ ទូរស័ព្ទ ០៣២ ៦១៩ ១២៩៥
**មជ្ឈមណ្ឌលទទួលការរិះគន់របស់អតិថិជន** ၊ ទូរស័ព្ទ ១៦៩៩ ៩៥៩៩ ទូរសារ ១៦៩៩ ៩៥៩៩



រាល់ការថតចម្លងដោយផ្នែកឬទាំងស្រុង ការបោះពុម្ពតាម ការផ្សព្វផ្សាយបន្ត ទៅលើឯកសារនេះ ដោយមិនមានការអនុញ្ញាតពីសាជីវកម្មសាធារណៈដើម្បីសុខភាពនិងសុវត្ថិភាព នឹងផ្ទុយនឹងច្បាប់កម្មសិទ្ធិបញ្ញា។

# 01 산업안전보건법 일반

- 산업안전보건법 목적
- 산업안전보건법 법령체계



# 01 ចំនុចទូទៅនៃច្បាប់សុវត្ថិភាព និងសុខភាពក្នុងការងារ

- គោលបំណងនៃច្បាប់សុវត្ថិភាព និងសុខភាពក្នុងការងារ
- ប្រព័ន្ធច្បាប់នៃច្បាប់សុវត្ថិភាព និងសុខភាពក្នុងការងារ



# 산업안전보건법 목적



산업안전보건에 관한 기준을 확립하고, 책임의 소재를 명확하게 하여 산업재해를 예방하고 쾌적한 작업환경을 조성함으로써, 근로자의 안전과 보건을 유지 · 증진함을 목적으로 한다.

**산업안전보건법 목적**

- 산업안전보건에 관한 **기준 확립**
- **책임**의 소재를 명확히
- 산업재해 예방, **쾌적한 작업환경** 조성
- 근로자의 **안전과 보건**을 유지 · 증진

# គោលបំណងនៃច្បាប់សុវត្ថិភាព និងសុខភាពក្នុងការងារ



គោលបំណងនៃច្បាប់នេះមានគោលបំណងក្នុងការរក្សានិងលើកកម្ពស់សុវត្ថិភាព និងសុខភាពរបស់អ្នកធ្វើការ
តាមរយៈបង្កើតស្តង់ដាទាក់ទងនឹងសុវត្ថិភាពនិងសុខភាពក្នុងការងារ បង្ការគ្រោះថ្នាក់ក្នុងការងារតាមរយៈការបញ្ជាក់ច្បាស់លាស់ពីទំនួលខុសត្រូវ និងបង្កើតបរីស្ថានការងារដ៏ស្រស់ថ្លា ។

**គោលបំណងនៃច្បាប់សុវត្ថិភាព និងសុខភាពក្នុងការងារ**

- បង្កើតស្តង់ដាទាក់ទងនឹងសុវត្ថិភាពនិងសុខភាពក្នុងការងារ
- បញ្ជាក់ច្បាស់លាស់ពីទំនួលខុសត្រូវ
- បង្ការគ្រោះថ្នាក់ក្នុងការងារ, បង្កើតបរិស្ថានការងារដ៏ស្រស់ថ្លា
- ការរក្សានិងលើកកម្ពស់សុវត្ថិភាព និងសុខភាពរបស់អ្នកធ្វើការ

# 산업안전보건법 법령체계

## > 산업안전보건법령 계층 구조도

<table>
<tr><th>제 · 개정권자</th><th colspan="3"></th><th>법적 성격</th></tr>
<tr><td>국민투표</td><td colspan="3">기본법(헌법)</td><td rowspan="5">법령<br>(형사처벌 및 경제력 제재 병행)</td></tr>
<tr><td>국회<br>환노위 ⇨ 법사위 ⇨ 본회의</td><td colspan="3">산업안전보건법(법률)</td></tr>
<tr><td>대통령<br>입법예고 ⇨ 규제심사 ⇨ 법제처 심사 ⇨ 차관회의 ⇨ 국무회의</td><td colspan="3">산업안전보건법 시행령(대통령령)</td></tr>
<tr><td rowspan="3">고용노동부 장관<br>입법예고 ⇨ 규제심사 ⇨ 법제처 심사</td><td colspan="3">고용노동부령(3개)</td></tr>
<tr><td>산업안전보건법 시행규칙</td><td>산업안전보건 기준에 관한 규칙</td><td>유해 · 위험작업의 취업 제한에 관한 규칙</td></tr>
<tr><td colspan="3">기술상의 지침 및 작업환경의 표준(고시), 예규, 훈령</td><td>행정규칙</td></tr>
</table>

**고용 감독** (고용노동부)

**기술 지원** (안전보건공단)

| 산업안전보건 관련 민간기관 | | | | | |
|---|---|---|---|---|---|
| 안전 · 보건관리 대행기관 | 재해 예방 전문지도기관 | 지정검사기관 | 특수건강 진단기관 | 작업환경 측정기관 | 산업안전 · 위생지도사 |

# ប្រព័ន្ធច្បាប់នៃច្បាប់សុវត្ថិភាព និងសុខភាពក្នុងការងារ

## > រចនាសម្ព័ន្ធនៅក្នុងច្បាប់សុវត្ថិភាព និងសុខភាពក្នុងការងារ

| អ្នកមានអំណាចអនុម័ត និងកែសម្រួលច្បាប់ | | លក្ខណៈច្បាប់ |
|---|---|---|
| ប្រជាមតិ | ច្បាប់គ្រឹះ[ច្បាប់រដ្ឋធម្មនុញ្ញ] | ច្បាប់ [ច្បាប់ទណ្ឌកម្មឧក្រិដ្ឋកម្ម និងទណ្ឌកម្មសេដ្ឋកិច្ច] |
| សភា<br>គណៈកម្មការបរិស្ថាននិងពលកម្ម ⇨ គណៈកម្មការច្បាប់និងតុលាការ ⇨ កិច្ចប្រជុំពេញអង្គ | ច្បាប់សុវត្ថិភាពនិងសុខភាពក្នុងការងារ[ច្បាប់] | |
| ក្រិត្រូវបស់ប្រធានាធិបតី<br>ប្រធានាធិបតី ⇨ ការប្រកាសច្បាប់ជាមុ ន ⇨ វង្វាយតម្លៃច្បាប់ ⇨ វង្វាយតម្លៃដោយការិយាល័យច្បាប់ ⇨ កិច្ចប្រជុំអនុរដ្ឋមន្ត្រី ⇨ កិច្ចប្រជុំគណៈរដ្ឋមន្ត្រី | សេចក្តីបញ្ញាឲ្យអនុម័តច្បាប់សុវត្ថិភាពនិងសុខភាពក្នុងការងារ[ក្រឹត្យរបស់ប្រធានាធិបតី] | |
| រដ្ឋមន្ត្រីនៃក្រសួងការងារនិងពលកម្ម<br>ការប្រកាសច្បាប់ជាមុន ⇨ វង្វាយតម្លៃច្បាប់ ⇨ វង្វាយតម្លៃដោយការិយាល័យច្បាប់ | សេចក្តីបញ្ជាក់របស់ក្រសួងការងារនិងពលកម្ម [៣ ក្រឹត្យ]<br>បទបញ្ញាអនុម័តច្បាប់សុវត្ថិភាពនិងសុខភាព / បទបញ្ញាទាក់ទងនឹងស្តង់ដាសុវត្ថិភាពនិងសុខភាពក្នុងការងារ / បទបញ្ញាទាក់ទងនឹងដែនកំនត់នៃការងារនៅក្នុងន្លែងគ្រោះថ្នាក់ | |
| | គោលការណ៍ណែនាំអំពីបច្ចេកទេស និងស្តង់ដាបរិស្ថានការងារ [សេចក្តីប្រកាស]បម្រុងប្រយ័ត្ន សេចក្តីបង្គាប់ | បទបញ្ញារដ្ឋបាល |

**ការអង្កេតការងារ**
[ក្រសួងការងារនិងពលកម្ម]

**ការទ្រទ្រង់បច្ចេកទេស**
[សាជីវកម្មសាធារណៈដើម្បីសុវត្ថិភាពនិងសុខភាព]

| ស្ថាប័យឯកជនទាក់ទងនឹងសុវត្ថិភាពនិងសុខភាពក្នុងការងារ | | | | | |
|---|---|---|---|---|---|
| ភ្នាក់ងារគ្រប់គ្រងសុវត្ថិភាពនិងសុខភាព | ស្ថាប័នដឹកនាំជំនាញបង្ការគ្រោះថ្នាក់ | ស្ថាប័នពិនិត្យដែលបានកំណត់ | ស្ថាប័នពិនិត្យសុខភាពពិសេស | ស្ថាប័នវាស់ស្ទង់បរិស្ថានការងារ | អ្នកណែនាំអំពីសុវត្ថិភាពការងារនិងអនាម័យ |

# 02 산업안전보건 각 주체들의 역할과 의무

- 사업주의 의무
- 근로자의 의무
- 정부의 책무



# 02 តួនាទីនិងកាតព្វកិច្ចនៃភាគីនីមួយៗ ចំពោះសុវត្ថិភាព និងសុខភាពក្នុងការងារ

- កាតព្វកិច្ចរបស់ម្ចាស់អាជីវកម្ម
- កាតព្វកិច្ចរបស់អ្នកធ្វើការ
- កាតព្វកិច្ចរបស់រដ្ឋាភិបាល



# 사업주의 의무

산업안전보건법에서는 산업안전보건을 위한 각 주체 즉, 정부, 사업주, 근로자의 책임과 의무에 대하여 규정하고 있으며 그중에서도 사업주의 의무에 대해서 구체적 강행규정을 두고 있다.



## 1 일반적 의무

사업주는 다음 각 호의 사항을 이행함으로써 근로자의 안전과 건강을 유지 · 증진시키는 한편, 국가의 산업재해 예방시책에 따라야 한다.

- 이 법과 이 법에 따른 명령으로 정하는 산업재해 예방을 위한 기준을 지킬 것
- 근로자의 신체적 피로와 정신적 스트레스 등을 줄일 수 있는 쾌적한 작업환경을 조성하고 근로조건을 개선할 것
- 해당 사업장의 안전과 보건에 관한 정보를 근로자에게 제공할 것

# កាតព្វកិច្ចរបស់ម្ចាស់អាជីវកម្ម

នៅក្នុងច្បាប់សុវត្ថិភាពនិងសុខភាពក្នុងការងារ មានចែងអំពីទំនួលខុសត្រូវ និងកាតព្វកិច្ចនៃភាគីនីមួយៗ ដូចជារដ្ឋាភិបាល ម្ចាស់អាជីវកម្ម អ្នកធ្វើការ ក្នុងចំណោមនេះ
កាតព្វកិច្ចរបស់ម្ចាស់អាជីវកម្មត្រូវបានចែងយ៉ាងលម្អិត និងតម្រូវឲ្យគោរពតាមជាកំហិត ។



## 1 កាតព្វកិច្ចទូទៅ

ម្ចាស់អាជីវកម្មត្រូវគោរពចំនុចខាងក្រោម ដើម្បីរក្សានិងលើកកម្ពស់សុវត្ថិភាព និងសុខភាពរបស់និយោជិក និងត្រូវអនុលោមទៅតាមគោលនយោបាយបង្ការគ្រោះថ្នាក់ការងារ ។

- ត្រូវតែគោរពទៅតាមច្បាប់នេះ និងស្តង់ដា សម្រាប់បង្ការគ្រោះថ្នាក់ក្នុងការងារ ដែលបានដាក់កំហិតឲ្យគោរពក្នុងច្បាប់នេះ ។
- ត្រូវតែបង្កើតបរិយាកាសការងារស្រស់ថ្លា ដែលអាចកាត់បន្ថយការនឿយហត់ផ្លូវកាយ និងផ្លូវចិត្តរបស់និយោជិក ។
- ត្រូវផ្តល់ព័ត៌មានអំពីសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ ដល់និយោជិក ។

## 2 설계 · 제조 · 수입 · 건설하는 자의 의무

다음 각 호의 어느 하나에 해당하는 자는 설계, 제조, 수입 또는 건설을 할 때 이 법과 이 법에 따른 명령으로 정하는 기준을 지켜야 하고, 그 물건을 사용함으로써 발생하는 산업재해를 방지하기 위하여 필요한 조치를 하여야 한다.

- 기계, 기구와 그 밖의 설비를 설계, 제조 또는 수입하는 자
- 원재료 등을 제조, 수입하는 자
- 건설물을 설계, 건설하는 자

## 3 산업재해 발생 기록 및 보고 의무

- 사망, 4일 이상의 요양이 필요한 부상을 입거나 질병에 걸린 경우
- 1개월 이내에 '산업재해조사표'를 관할 지방고용노동관서의 장에게 제출하여야 한다

## 4 법령 요지 게시 등의 의무

- 산업안전보건법과 이 법에 따른 명령의 요지를 상시 각 작업장 내에 근로자가 쉽게 볼 수 있는 장소에 게시하거나 갖추어두어 근로자로 하여금 알게 하여야 한다
- 사업주는 산업안전보건위원회 의결사항 등을 근로자 대표가 요구하는 경우 성실히 통지하여야 한다

* **근로자 대표 요청사항** : 산업안전보건위원회 (또는 노사협의체) 의결사항, 안전보건관리규정 내용, 도급사업 시의 안전보건 조치, 물질안전보건 자료, 작업환경 측정에 관한 사항, 안전 · 보건 진단 결과, 안전보건 개선계획의 수립 · 시행 내용

## 2 កាតព្វកិច្ចរបស់អ្នកដែលគ្រោង បង្កើត នាំចូល និងសាងសង់

ជនដែលស្ថិតនៅក្នុងចំណុចខាងក្រោម នៅពេលគ្រោង បង្កើត នាំចូល ឬសាងសង់ ត្រូវតែគោរពទៅតាមច្បាប់ និងស្តង់ដាដែលបានចែងជាបទបញ្ញានៅក្នុងច្បាប់ ហើយត្រូវតែចាត់វិធានការចាំបាច់ ដើម្បីបង្ការគ្រោះថ្នាក់ នៅពេលដែលប្រើវត្ថុទាំងនោះ ។

- ជនដែលគ្រោង ផលិត និងនាំចូលម៉ាស៊ីន សម្ភា: និងរបស់ផ្សេងៗទៀត
- ជនដែលផលិត ឬនាំចូលវត្ថុធាតុដើម
- ជនដែលគ្រោង និងសាងសង់អគារ

## 3 កាតព្វកិច្ចកត់ត្រាហេតុការណ៍គ្រោះថ្នាក់ និងរាយការណ៍

- ករណីដែលមានមនុស្សស្លាប់ រងរបួសដែលត្រូវការព្យាបាលលើសពី ៤ថ្ងៃ ឬក៏ឆ្លងជម្ងឺ
- ត្រូវដាក់ "តារាងស្រង់ព័ត៌មានគ្រោះថ្នាក់ការងារ" ទៅកាន់ប្រធាន ការិយាល័យរដ្ឋាភិបាលផ្នែកការងារនិងពលកម្ម ដែលទទួលបន្ទុក ក្នុងកំឡុងពេល ១ខែ ។

## 4 កាតព្វកិច្ចបង្ហាញមាត្រាច្បាប់

- នៅក្នុងកន្លែងការងារ ត្រូវតែមានបង្ហាញបទបញ្ញា នៃច្បាប់សុវត្ថិភាពនិងសុខភាពក្នុងការងារ ឲ្យនិយោជិកងាយស្រួលមើល ឬក៏ប្រើមធ្យោបាយផ្សេងដើម្បីឲ្យនិយោជិកដឹងអំពីច្បាប់ ។
- ម្ចាស់អាជីវកម្ម ត្រូវតែប្រកាសដំណឹងឲ្យបានល្អ អំពី ចំណុចដែលបានសម្រេចដោយគណៈកម្មការដើម្បីសុវត្ថិភាព និងសុខភាពក្នុងការងារ ករណីអ្នកតំណាងនិយោជិកស្នើសុំ ។

* ចំណុចស្នើសុំដោយអ្នកតំណាងនិយោជិកៈ ចំណុចសម្រេចដោយគណៈកម្មការដើម្បីសុវត្ថិភាពនិងសុខភាព(ឬ សហជីពពលករ), អត្ថន័យនៃគោលការណ៍ណែនាំអំពីការគ្រប់គ្រងសុវត្ថិភាពនិងសុខភាព, វិធានការសុវត្ថិភាពនិងសុខភាពសម្រាប់អាជីវកម្មចុះកុងត្រាបន្ត, ឯកសារសុវត្ថិភាពនិងសុខភាពរបស់វត្ថុធាតុ, ចំណុចទាក់ទងនឹងការវាស់ស្ទង់បរិយាកាសការងារ, លទ្ធផលពិនិត្យសុវត្ថិភាពនិងសុខភាព, មាតិកាអំពីការបង្កើតនិងអនុវត្តគម្រោងលើកកម្ពស់សុវត្ថិភាពនិងសុខភាព




## 5 안전보건 표지 부착 등의 의무

- 유해하거나 위험한 시설 및 장소에 대한 경고
- 비상시 조치에 대한 안내
- 그 밖에 안전의식의 고취를 위하여 안전 · 보건 표지를 근로자가 쉽게 알아볼 수 있는 장소, 시설 또는 물체에 설치하거나 부착하여야 한다
- 외국인 근로자를 채용한 사업주는 외국어로 된 안전보건 표지와 작업안전수칙을 부착하도록 노력하여야 한다

## 6 교육훈련 실시 의무

- 정기교육
- 채용 시 교육
- 작업내용 변경 시 교육
- 특별교육

## 7 유해 · 위험한 기계 및 기구 등의 방호조치

사업주는 방호조치가 정상적인 기능을 발휘할 수 있도록 상시 점검하고 정비하여야 하며, 근로자가 방호장치의 기능이 상실된 것을 발견하고 이를 신고한 때에는 즉시 수리, 보수 및 작업 중지 등의 적절한 조치를 취해야 한다.




## 5 កាតព្វកិច្ចបិទសញ្ញាសុវត្ថិភាពនិងសុខភាព

- សញ្ញាដាស់តឿនអំពីកន្លែង និងបរិក្ខារ ដែលមានគ្រោះថ្នាក់
- ព័ត៌មានអំពីវិធានការពេលអាសន្ន
- ត្រូវបិទសញ្ញាសុវត្ថិភាពនិងសុខភាពនៅកន្លែងដែលនិយោជិកអាចមើលបានស្រួល បិទឬដំឡើង លើបរិក្ខារ ឬវត្ថុ ដើម្បីទាញចំណាប់អារម្មណ៍របស់និយោជិកលើសុវត្ថិភាព ។
- សម្រាប់ម្ចាស់អាជីវកម្មដែលជួលនិយោជិកបរទេស ត្រូវតែខិតខំបិទសញ្ញាសុវត្ថិភាពនិងសុខភាព និងវិន័យសុវត្ថិភាពការងារជាភាសាបរទេស ។

## 6 កាតព្វកិច្ចអនុវត្តការអប់រំហ្វឹកហាត់

- ការអប់រំរយៈពេលវែង
- ការអប់រំពេលជួលធ្វើការ
- ការអប់រំពេលផ្លាស់ប្តូរប្រភេទការងារ
- ការអប់រំពិសេស

## 7 វិធានការការពារម៉ាស៊ីនឬសម្ភារៈគ្រោះថ្នាក់

ម្ចាស់អាជីវកម្មត្រូវធ្វើការត្រួតពិនិត្យនិងបន្តថែរក្សាវិធានការការពារឲ្យបានទៀងទាត់ ដើម្បីធ្វើយ៉ាងណាអោយម៉ាស៊ីន និងឧបករណ៍ដំណើរការទៅជាធម្មតា។ ប្រសិនជាកម្មករកំណត់ និងរាយការណ៍នូវវិធានការការពារដែលដំណើរការមិនប្រក្រតី និយោជកត្រូវតែចាត់វិធានការសមស្របដូចជាការជួសជុល និងបង្អាក់ការងារភ្លាមៗ ។




## 8 유해인자 허용 기준의 준수

발암물질 등 근로자에게 중대한 건강 장해를 유발할 우려가 있는 유해인자로서 작업장 내 유해인자의 노출 농도를 고용노동부령으로 정하는 허용기준 이하로 유지하여야 한다.

## 9 화학물질의 유해성, 위험성 조사

신규 화학물질에 의한 근로자의 건강 장해를 예방하고 우리나라가 유해물질의 독성 실험장소로 사용되는 것을 방지하기 위해 신규 화학물질 제조·수입자에게 유해성 및 위험성 조사보고서 제출 의무를 부과하고 있다.

## 10 물질안전보건 자료의 작성 · 비치 등

대상 화학물질을 취급하려는 근로자에게 자신이 취급하는 대상 화학물질의 유해·위험성 등을 알려줌으로써 대상 화학물질 취급 시 발생될 수 있는 산업재해나 직업병을 사전에 예방하고 불의의 사고에도 신속히 대응하도록 하기 위해 사업주에게 화학물질의 명칭, 성분, 함유량, 안전보건상의 취급 시 주의사항 등을 게시하거나 갖춰두도록 하고 있다.




## 8 ការគោរពនៃស្តង់ដាអនុញ្ញាតកត្តាគ្រោះថ្នាក់

នៅកន្លែងធ្វើការ កម្រិតកំហាប់នៃការលេចចេញនូវកត្តាគ្រោះថ្នាក់ដែលអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពរបស់និយោជិកដូចជាសារធាតុបង្កមហារីក ត្រូវតែស្ថិតនៅក្រោមកម្រិតអនុញ្ញាត ដោយបទញ្ញានៃក្រសួងការងារនិងពលកម្ម ។

## 9 ការប្រមូលព័ត៌មានអំពីកម្រិតពុលនិងគ្រោះថ្នាក់របស់សារធាតុគីមី

ដើម្បីបង្ការគ្រោះថ្នាក់នៃសុខភាពរបស់និយោជិក ដោយសារតែសារធាតុគីមីថ្មី និងបង្ការការប្រើប្រាស់ប្រទេសកូរ៉េ ជាកន្លែងពិសោធន៍សារធាតុពុល ជនដែលផលិតឬនាំចូលសារធាតុគីមីថ្មី មានកាតព្វកិច្ចដាក់ របាយការណ៍ព័ត៌មានអំពីកម្រិតពុលនិងគ្រោះថ្នាក់ ។

## 10 ការបង្កើតនិងចែករំលែកឯកសារសុវត្ថិភាពនិងសុខភាព

ម្ចាស់អាជីវកម្មមានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានអំពីបម្រុងប្រយ័ត្នពេលបំពេញការងារ ឈ្មោះ ធាតុផ្សំ បរិមាណនៃធាតុបន្សំ កម្រិតសុវត្ថិភាពរបស់សារធាតុគីមី និងដំណឹងអំពីកម្រិតពុល និងគ្រោះថ្នាក់របស់សារធាតុគីមី ដែលនិយោជិកនឹងធ្វើការទាក់ទងជាមួយ ដើម្បីបង្ការគ្រោះថ្នាក់ក្នុងការងារនិងជម្ងឺក្នុងការងារ ដែលអាចកើតឡើងដោយសារសារធាតុគីមី និងអាចធ្វើសកម្មភាពបានរហ័សនៅពេលមានឧបទ្ទវហេតុកើតឡើង ។

## 경고 표지의 작성 예시 및 방법

* 산업안전보건법 제 41조에 의한 경고표시 예시

**벤젠** (CAS No. 71-43-2)



**신호어 : 위험**

**유해 · 위험문구**

- 고인화성 액체 또는 증기
- 삼키면 유해함
- 삼켜서 기도로 유입되면 치명적일 수 있음
- 피부에 자극을 일으킴
- 눈에 심한 자극을 일으킴
- 졸음 또는 현기증을 일으킬수 있음
- 유전적인 결함을 일으킬 것으로 의심됨
- 암을 일으킬수 있음
- 태아 또는 생식능력에 손상을 일으킬 것으로 의심됨
- 호흡기 및 장기에 손상을 일으킴
- 장시간 또는 반복적으로 노출되면 (중추신경계, 조혈계)장기에 손상을 일으킴
- 정기적인 영향에 의해 수생생물에게 독성이 있음

**예방조치 문구**

- 예방 : 열, 스파크, 화염, 고열로부터 멀리하시오.
  이 제품을 사용할 때에는 먹거나, 마시거나 흡연하지 마시오.
  옥외 또는 환기가 잘되는 곳에서만 취급하시오.
  보호장갑, 보호의, 보안경, 안면보호구를 착용하시오.
- 대응 : 흡입하면 신선한 공기가 있는 곳으로 옮기고 호흡하기 쉬운 자세로 안전을 취하시오.
  삼켰다면, 입을 씻어내시오. 토하게 하려 하지 마시오.
  피부(또는 머리카락)에 묻으면 오염된 모든 의복을 벗거나 제거하시오.
  피부를 물로 씻으시오. 샤워하시오.
  눈에 묻으면 몇 분간 물로 조심해서 씻으시오. 가능하면 콘텍트렌즈를
  제거하시오. 계속 씻으시오.
- 저장 : 용기는 환기가 잘되는 곳에 단단히 밀폐하여 보관하고 저온으로 유지하시오.
- 폐기 : (관련법규에 명시된 내용에 따라) 내용물 · 용기를 폐기하시오.
- 공급자 정보 : 제조자 또는 공급자의 이름, 주소 및 전화번호

| | | |
|---|---|---|
| **명칭** | • 대상 화학물질의 명칭 | |
| **그림문자** | • 5개 이상일 경우 4개만 표시 | |
| **신호어** | • '위험' 또는 '경고' 표시 | • 모두 해당 : '위험'만 표시 |
| **유해 · 위험 문구** | • 해당 문구 모두 기재<br>• 유사한 문구 조합 가능 | • 중복되는 문구 생략 |
| **예방조치 문구** | • 예방, 대응, 저장, 폐기 각 1개 이상을 포함하여 6개만 표시 가능 | |
| **공급자 정보** | • 제조자 또는 공급자의 이름, 주소 및 전화번호 기재 | |

## ឧទាហរណ៍ និងវិធីអំពីការបង្កើតសញ្ញាព្រមាន

* ឧទាហរណ៍អំពីសញ្ញាព្រមានដោយយោងទៅតាមមាត្រាទី ៩១ នៃច្បាប់សុវត្ថិភាពនិងសុខភាពការងារ

### ប៉ង់សែន (CAS No. 71-43-2)



ប្រភេទសញ្ញា៖ គ្រោះថ្នាក់

### ឃ្លាបញ្ជាក់ពីភាពគ្រោះថ្នាក់

- អង្គធាតុរាវឬឧស្ម័នងាយឆាបឆេះ
- ពុលបើសិនជាលេបចូល
- អាចមានគ្រោះថ្នាក់ដល់ស្លាប់ បើសិនជាចូលក្នុងផ្លូវខ្យល់ដង្ហើម ក្រោយពេលលេប
- ប្រតិកម្មនឹងស្បែក
- ប្រតិកម្មខ្លាំងនឹងភ្នែក
- អាចបង្កឲ្យងងុយ ឬវិលមុខ
- សង្ស័យថាជាមូលហេតុបង្កការខូចហ្សែន
- អាចបង្កមហារីក
- សង្ស័យថាជាមូលហេតុបង្កការខូចប្រព័ន្ធបន្តពូជ
- បង្កឲ្យប្រព័ន្ធដង្ហើម និងគ្រឿងក្នុង
- បង្កឲ្យខូចគ្រឿងក្នុង បើសិនត្រូវរយៈពេលយូរ ឬច្រើនលើក (ប្រព័ន្ធប្រសាទ ប្រព័ន្ធឈាម)
- មានសារធាតុពុលដល់មច្ឆាជាតិ ដោយសារតែឥទ្ធិពលជាទៀតទាត់

### ឃ្លាសម្រាប់វិធានការបង្ការ

- បង្ការ៖ សូមនៅឆ្ងាយពីកម្តៅ ផ្កាភ្លើង អណ្តាតភ្លើង និងកម្តៅខ្ពស់។មិនត្រូវលេបចូល ផឹក ឬបឺតផលិតចូលឡើយ ។
  ត្រូវតែធ្វើការនៅក្រៅបន្ទប់ ឬកន្លែងដែលមានខ្យល់ចេញចូលគ្រប់គ្រាន់ ។
  សូមពាក់ស្រោមដៃសុវត្ថិភាព សម្លៀកបំពាក់សុវត្ថិភាព វ៉ែនតាសុវត្ថិភាព និងរបាំងមុខការពារសុវត្ថិភាព ។
- វិធានការ៖ បើសិនស្រូបចូលក្នុងខ្លួន ត្រូវប្រញាប់ទៅកន្លែងដែលមានខ្យល់ល្អ និងរក្សាខ្លួនឲ្យងាយដកដង្ហើម ។
  បើសិនជាលេបចូល សូមលាងមាត់ មិនត្រូវធ្វើឲ្យក្អួតឡើយ ។
  បើសិនជាប្រឡាក់ជាប់ស្បែក (និងសរសៃសក់) ត្រូវដោះសម្លៀកបំពាក់ទាំងអស់ដែលបានប្រឡាក់ និងលាងសម្អាត ។
  សូមលាងស្បែកជាមួយនឹងទឹក សូមងូតទឹកសម្អាត ។
  បើសិនជាចូលភ្នែក សូមលាងនឹងទឹកដោយប្រុងប្រយ័ត្ន ។ បើសិនជាអាចទៅរួច សូមដោះលែនចេញ ។ បន្តការលាងសម្អាត ។
- ការស្តុកទុក៖ សូមបិទធុងឲ្យជិតល្អ និងរក្សា នៅក្នុងកន្លែងដែលមានខ្យល់ចេញចូលល្អ និង រក្សាសីតុណ្ហភាពត្រជាក់ ។
- ការបោះចោល៖ (ដោយទៅតាមមាត្រាចែងក្នុងច្បាប់ដែលពាក់ព័ន្ធ) សូមបោះធុងនិងអ្វីដែលនៅខាងក្នុងចោល។
- ព័ត៌មានអ្នកផ្គត់ផ្គង់៖ឈ្មោះ អាស័យដ្ឋាន និងលេខទូរស័ព្ទរបស់អ្នកផលិត ឬអ្នកផ្គត់ផ្គត់។

| | |
|---|---|
| ឈ្មោះ | • ឈ្មោះរបស់សារធាតុគីមី |
| អក្សរបែបរូបភាព | • បើសិនជាលើសពី៥ សូមបង្ហាញតែ ៤ |
| ប្រភេទសញ្ញា | • សញ្ញា "គ្រោះថ្នាក់" ឬ "ព្រមាន" • ត្រូវគ្រប់ករណី៖ សញ្ញា "គ្រោះថ្នាក់" |
| ឃ្លាបញ្ជាក់ពីភាពគ្រោះថ្នាក់ | • សរសេរឃ្លាទាំងអស់ • លុបឃ្លាដែលត្រួតគ្នា • ឃ្លាដែលស្រដៀងគ្នាអាចបញ្ចូលគ្នាបាន |
| ឃ្លាវិធានការបង្ការ | • អាចបង្ហាញបានចំនួន ៦ ដែលមានផ្នកនូវ ការបង្ការ វិធានការ ការផ្ទុកទុក ការបោះចោល លើសពី១សម្រាប់ចំណុចនីមួយៗ ។ |
| ព័ត៌មានរបស់អ្នកផ្គត់ផ្គត់ | • សរសេរឈ្មោះ អាស័យដ្ឋាន និងលេខទូរស័ព្ទរបស់អ្នកផលិត ឬអ្នកផ្គត់ផ្គត់ |

## Check Box

- **GHS기준에 따른 적용 시기**
  - 단일물질 : 2010. 6. 30까지 유예기간, 2010. 7. 1일부터 전면 시행
  - 혼합물질 : 2013. 6. 30까지 유예기간, 2013. 7. 1일부터 전면 시행

- **GHS기준에 의한 MSDS 변경 내용**
  - 화학물질의 분류 기준 및 경고 표지의 그림문자가 국제적으로 통일됨

### GHS기준에 의한 MSDS 변경 내용





**MSDS**

화학물질을 안전하게 사용하고 관리하기 위하여 필요한 정보를 기재한 Sheet. 제조자명, 제품명, 성분과 성질, 취급상의 주의, 적용법규, 사고 시의 응급처치방법 등이 기입되어 있다

## ប្រអប់ពិនិត្យ

- ពេលអនុវត្តទៅតាមស្តង់ដា GHS
  - សារធាតុតែមួយ៖ រយៈពេលមិនទាន់អនុវត្ត ដល់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០, អនុវត្តទាំងស្រុងចាប់ពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០០៧
  - សាធាតុបន្សំ៖ រយៈពេលមិនទាន់អនុវត្ត ដល់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០, អនុវត្តទាំងស្រុងចាប់ពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០០៧
- មាតិកាផ្លាស់ប្តូរ MSDS ដោយយោងទៅតាមGHS
  - ស្តង់ដាបែងចែកសារធាតុគីមី និងអក្សរបែបរូបភាពនៃសញ្ញាព្រមានត្រូវដូចទៅនឹងអន្តរជាតិ

### មាតិកាផ្លាស់ប្តូរ MSDS ដោយយោង ទៅតាមGHS







**MSDS**

វាគឺជាតារាងព័ត៌មាន ដែលមានផ្ទុកព័ត៌មានចាំបាច់ ដើម្បីគ្រប់គ្រង និងប្រើប្រាស់សារធាតុគីមីប្រកបដោយសុវត្ថិភាព ។
វាមានផ្ទុកឈ្មោះអ្នកផលិត ឈ្មោះផលិតផល ធាតុផ្សំ លក្ខណៈបម្រុងប្រយ័ត្ន ច្បាប់ដែលអនុវត្ត និងវិធានការស្រាយពេលមានគ្រោះថ្នាក់ ។




## 11 위험성 평가

'사업장 위험성 평가에 관한 지침'(고용노동부 고시 제2012-104호)에 따라 2013. 1. 1 부터 위험성 평가사업 전면 시행.

## 12 작업환경 측정

유해인자로부터 근로자의 건강을 보호하고 쾌적한 작업환경을 조성하기 위하여 사업주로 하여금 인체에 해로운 작업을 하는 작업장에 대해 작업환경 측정을 실시하고 그 결과를 기록, 보존하며 고용노동부 장관에게 보고하여야 한다.

## 13 근로자 건강진단

건강진단을 통해 질병 또는 직업성 질환을 초기 단계에서 찾아내어 진행을 사전에 예방하는 것이 필수적이므로 사업주에게 근로자에 대한 건강진단 실시 의무를 부과하고 있다.




**11 វាយតម្លៃកម្រិតគ្រោះថ្នាក់**

អនុវត្តកម្មវិធីវង្វាយតម្លៃកម្រិតគ្រោះថ្នាក់ចាប់ពីថ្ងៃ១ ខែមករា ឆ្នាំ ២០១៣ ដោយយោងទៅតាម "គោលការណ៍ណែនាំទាក់ទងនឹងវង្វាយតម្លៃកម្រិតគ្រោះថ្នាក់នៅកន្លែងការងារ" [សេចក្តីប្រកាសនៃក្រសួងការងារនិងពលកម្ម លេខ២០១២-១០៤]

**12 ការវាស់ស្ទង់បរិស្ថានការងារ**

ដើម្បីការពារសុខភាពរបស់អ្នកធ្វើការពីកត្តាគ្រោះថ្នាក់ និងបង្កើតបរិស្ថានការងារដ៏ស្រស់ថ្លា ម្ចាស់អាជីវកម្មត្រូវតែធ្វើការវាស់ស្ទង់កម្រិតគ្រោះថ្នាក់នៃបរិស្ថានកន្លែងការងារ ដែលត្រូវធ្វើការទាក់ទងនឹងសារធាតុពុល ហើយកត់ត្រានិងរក្សាទុកលទ្ធផល ហើយត្រូវដាក់រាយការណ៍ទៅកាន់រដ្ឋមន្ត្រីនៃក្រសួងការងារនិងពលកម្ម ។

**13 ការពិនិត្យសុខភាពរបស់និយោជិក**

វាជាការចាំបាច់ក្នុងការបង្ការជម្ងឺ បញ្ហាសុខភាពរបស់និយោជិក តាមរយៈការពិនិត្យសុខភាព ដើម្បីស្វែងរកបញ្ហាសុខភាពក្នុងដំណាក់កាលដំបូង ដូចនេះម្ចាស់អាជីវកម្មត្រូវមានកាតព្វកិច្ចក្នុងការពិនិត្យសុខភាពរបស់និយោជិក ។




## 14 역학조사

고용노동부 장관은 기존의 작업환경 측정 또는 건강진단 등의 방법을 통하여 질병의 발생 원인 등을 규명하기 어려운 신종 직업성 질환을 밝혀내기 위해 역학조사를 실시할 수 있고, 사업주와 근로자는 이에 적극 협조하여야 한다.

## 15 건강관리수첩

건강장해 발생 우려가 있는 업무에 종사하는 근로자의 직업성 질환을 조기에 발견하고 지속적인 관리를 돕기 위해 건강관리수첩 제도를 도입하였다.

## 16 질병자의 근로 금지 · 제한

사업주는 감염병, 정신병 또는 근로로 말미암아 병세가 크게 악화될 우려가 있는 질병에 걸린 자에게는 의사의 진단에 따라 근로를 금지하거나 제한하여야 한다.




## 14 ការប្រមូលព័ត៌មានអំពីចលករ

រដ្ឋមន្ត្រីនៃក្រសួងការងារនិងពលកម្ម អាចធ្វើការប្រមូលព័ត៌មានអំពីចលករ ដើម្បីរកឲ្យឃើញនូវប្រភពជម្ងឺប្រភេទថ្មីក្នុងការងារដែលមានការលំបាកក្នុងការស្វែងរក តាមរយៈការវាស់ស្ទង់បរិស្ថានការងារ និងការពិនិត្យសុខភាព។ និយោជក និងនិយោជិកត្រូវតែចូលរួមសហការដោយសកម្ម។

## 15 សៀវភៅគ្រប់គ្រងសុខភាព

ដើម្បីស្វែងរកឲ្យឃើញនូវជម្ងឺការងារដំណាក់កាលដំបូងរបស់និយោជិក ដែលធ្វើការនៅក្នុងកន្លែងដែលអាចប៉ះពាល់ដល់សុខភាពខ្លាំង និងដើម្បីជួយដល់ការគ្រប់គ្រងសុខភាពដោយឥតដាច់ ប្រព័ន្ធប្រើប្រាស់សៀវភៅគ្រប់គ្រងសុខភាពត្រូវតែអនុវត្ត ។

## 16 កំហិតនិងការហាមឃាត់ការងាររបស់និយោជិកដែលមានជម្ងឺ

ម្ចាស់អាជីវកម្មត្រូវតែកំហិតឬហាមឃាត់ការងារ ដោយយោងទៅតាមលទ្ធផលពិនិត្យសុខភាពការងាររបស់និយោជិក ដែលបានឆ្លងជម្ងឺឆ្លងឬជម្ងឺផ្លូវចិត្តនិងវិវត្តទៅជាធ្ងន់ធ្ងរ ។

## 17 근로시간 연장의 제한

유해 또는 위험한 작업 시 그 작업에 직접 종사하는 시간을 제한하지 않으면 해당 근로자의 건강을 해치고 직업병에 걸릴 가능성이 크다는 점을 감안하여, 사업주로 하여금 고기압 조건에서 행하는 잠함 · 잠수작업 등 유해하거나 위험한 작업에 종사하는 근로자에 대하여는 1일 6시간, 1주 34시간을 초과하여 근로하지 못하도록 하고 있다.

## 18 자격 등에 의한 취업 제한

(법 제47조)

유해 또는 위험한 작업으로서 고용노동부령으로 정하는 작업에 있어서는 그 작업에 필요한 자격, 면허, 경험 또는 기능을 가진 근로자 외의 사람을 해당 작업에 임할 수 없도록 정하고 있다. (자세한 사항은 '유해 · 위험작업의 취업 제한에 관한 규칙' 참조).

## 19 유해 · 위험 방지계획서

재해 위험이 높은 건설물, 기계, 기구, 설비 등의 설치, 이전, 변경으로 인해 근로자의 안전과 보건을 해칠 우려가 있다는 점을 감안하여 유해 · 위험요인을 사전에 평가하기 위한 제도로서 사업주에게 미리 유해 · 위험 방지계획을 수립, 제출하도록 하여 정부가 이를 심사, 확인함으로써 유해 · 위험요인으로부터 근로자를 보호하기 위한 것이다.



## 17 កំហិតការងារលើសម៉ោង

សម្រាប់ការងារដែលមានគ្រោះថ្នាក់ បើសិនជាមិនកំហិតម៉ោងធ្វើការនៅក្នុងនោះទេ និយោជិកអាចនឹងមានបញ្ហាសុខភាព និងងាយនឹងឆ្លងជម្ងឺការងារ ។ ដូចនេះម្ចាស់អាជីវកម្មត្រូវតែ កំហិតម៉ោងមិនឲ្យលើសពី ៦ម៉ោងក្នុង ១ថ្ងៃ និង ៣៤ម៉ោងក្នុង១សប្តាហ៍ សម្រាប់និយោជិកដែលត្រូវធ្វើការនៅក្នុងកន្លែងគ្រោះថ្នាក់ ឬពុល ដូចជាការងារនៅក្រោមទឹក ដែលមានសម្ពាធខ្ពស់ ។

## 18 កំហិតការងារដោយយោងទៅតាមកម្រិតវប្បធម៌ [មាត្រាទី៨៧]

ដោយសារតាមបទបញ្ញាពីក្រសួងការងារ និងពលកម្ម សម្រាប់ការងារដែលមានគ្រោះថ្នាក់ ជនដែលក្រៅពីនិយោជិកដែលមកម្រិតវប្បធម៌ អាជ្ញាប័ណ្ណ បទពិសោធន៍ ឬមុខងារ មិនត្រូវបានអនុញ្ញាតធ្វើកិច្ចការនោះឡើយ ។

[ចំណុចដែលបានបង្ហាញ យោងទៅតាម "បទបញ្ញាទាក់ទងនឹងកំហិតការងារក្នុងកិច្ចការគ្រោះថ្នាក់"]

## 19 សៀវភៅគម្រោងបង្ការគ្រោះថ្នាក់

ដោយគិតទៅលើកត្តាសុវត្ថិភាពនិងសុខភាពរបស់និយោជិក ដោយសារការដំឡើង ការប្តូរទីតាំង ការផ្លាស់ប្តូរនៃ សំភារៈសំណង់ ម៉ាស៊ីន ឧបករណ៍ និងបរិក្ខារ ដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ ម្ចាស់អាជីវកម្មត្រូវបានតម្រូវឲ្យបង្កើតគម្រោង និងដាក់ជូនរដ្ឋាភិបាលជាមុន ដែលជាផ្នែកមួយនៃ ប្រព័ន្ធវាយតម្លៃកត្តាគ្រោះថ្នាក់ជាមុន ហើយរដ្ឋាភិបាលនឹងពិនិត្យ និងផ្ទៀតផ្ទាត់របាយការណ៍នេះ ដើម្បីការពារនិយោជិកពីកត្តាគ្រោះថ្នាក់ ។






## 20 안전보건 진단

산업재해를 예방하기 위해 잠재적 위험요인을 발견하고 그 대책을 수립할 수 있도록 중대 재해 발생사업장 등 고용노동부령으로 정하는 사업장에 대해 안전보건 진단기관의 안전보건 진단을 받도록 명령할 수 있는 제도이다. 즉, 재해 다발 사업장에 대하여 고용노동부 장관의 명령으로 전문성을 지닌 안전보건 진단기관에 의한 위험성 분석 등을 통하여 좀 더 구체적인 재해 예방대책을 수립, 시행함으로써 유해 · 위험요인으로부터 근로자를 보호하기 위한 것이다.

## 21 공정안전 보고서 제출 (법 제49조의 2)

화재, 폭발, 위험물질 누출로 사업장 내의 근로자에게 즉시 피해를 주거나 사업장 인근지역에 피해를 줄 수 있는 중대 산업사고 예방을 위한 공정안전 관리 제도 (PSM : Process Safety Management System)에 따라 공정안전 보고서를 공단에 제출하여 심사 및 확인을 받고 그 내용을 이행하여야 한다.

## 22 안전보건 개선 계획 (법 제50조)

재해 다발 또는 작업환경 불량 사업장에 대하여 고용노동부 장관의 명령을 통해 산업재해 예방을 위한 종합적인 개선조치를 하게 함으로써 유해 · 위험요인으로부터 근로자를 보호하기 위한 제도이다.




## 20 ការពិនិត្យសុវត្ថិភាពនិងសុខភាព

នេះជាប្រព័ន្ធដែលទីកន្លែងការងារដែលបានចែងនៅក្នុងបទបញ្ញត្តិនៃក្រសួងការងារ និងពលកម្ម ដូចជាកន្លែងដែលកើតមានឧបទ្ទវហេតុធ្ងន់ធ្ងរ ត្រូវតែទទួលការពិនិត្យសុវត្ថិភាពនិងសុខភាពពីស្ថាប័នទទួលបន្ទុក ដើម្បីបង្ការគ្រោះថ្នាក់ការងារ តាមរយៈការរកឲ្យឃើញនូវកត្តា ហានិភ័យដែលមានសក្តានុពល ដើម្បីបង្កើតវិធាន។ ប្រព័ន្ធនេះត្រូវបានបង្កើតឡើង ដើម្បីការពារនិយោជិកពីកត្តាហានិភ័យ តាមរយៈបទបញ្ញត្តិនៃក្រសួងការងារនិងពលកម្ម ដែលតម្រូវឲ្យកន្លែងការងារដែលធ្លាប់កើតគ្រោះថ្នាក់លើ ទទួលការពិនិត្យសុវត្ថិភាពនិងសុខភាព និងវិភាគលទ្ធផលឲ្យបានលម្អិត ដើម្បីបង្កើតនិងអនុវត្តវិធានការបង្ការ ។

## 21 ការដាក់របាយការណ៍សុវត្ថិភាពការងារ

[ចំណុចទី២ នៃមាត្រាទី ៤៩]

ដើម្បីបង្ការផលប៉ះពាល់នៃគ្រោះមហន្តរាយធ្ងន់ធ្ងរកន្លែងធ្វើការ ដូចជាមានអគ្គីភ័យ បន្ទុះ ការលេចចេញនៃសារធាតុពុល ដល់និយោជិកនៅទៅនោះ ឬតំបន់ក្បែរនោះ ម្ចាស់អាជីវកម្មត្រូវដាក់របាយការណ៍សុវត្ថិភាពការងារទៅកាន់សាជីវកម្មសាធារណៈដើម្បីទទួលការពិនិត្យ ផ្ទៀងផ្ទាត់ ដោយយោងទៅតាមប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពការងារ [PSM : Process Safety Management System] ។

## 22 គម្រោងលើកកម្ពស់សុវត្ថិភាពនិងសុខភាព

[មាត្រាទី ៥០]

វាជាប្រព័ន្ធដែលតម្រូវឲ្យមានវិធានការកែតម្រូវដើម្បីបង្ការគ្រោះថ្នាក់ការងារ តាមរយៈបទបញ្ជារបស់រដ្ឋមន្ត្រីនៃក្រសួងការងារនិងពលកម្ម សម្រាប់ទីកន្លែងការងារដែលមានឧបទ្ទវហេតុច្រើនលើក ឬបរិស្ថានការងារមិនល្អ ក្នុងគោលបំណងការងារនិយោជិកពីកត្តាគ្រោះថ្នាក់ ។

# 근로자의 의무

## 1 일반 의무

‘근로자는 법과 법에 대한 명령으로 정하는 산업재해 예방을 위한 기준을 지켜야 하며, 사업주나 그 밖의 관련 단체에서 실시하는 산업재해 방지에 관한 조치에 따라야 한다’라고 규정하여 근로자의 일반적인 의무에 대해 규정하고 있다.

## 2 준수사항

사업주가 취한 안전조치와 보건조치를 준수하여야 한다.

## 3 그 밖의 의무

- 근로자는 산업안전보건위원회의 심의, 의결 또는 결정사항을 성실히 이행하여야 한다
- 수급인의 근로자는 도급인이 하는 조치 또는 요구에 따라야 한다
- 사업주가 실시하는 건강진단을 받아야 한다
- 역학조사 실시 시 협조하여야 한다
- 공정안전 보고서의 내용 및 안전보건 개선계획을 준수하여야 한다
- 안전보건 관리규정을 준수하여야 한다
- 방호조치에 대한 근로자 준수사항

  근로자는 방호조치를 해제하고자 하는 경우 사업주의 허가를 받아야 하며, 방호조치를 해제한 후 그 사유가 소멸한 때에는 지체 없이 원상회복해야 하고, 방호조치의 기능이 상실된 것을 발견한 때에는 지체 없이 사업주에게 신고하여야 한다

# កាតព្វកិច្ចរបស់អ្នកធ្វើការ

## 1 កាតព្វកិច្ចទូទៅ

កាតព្វកិច្ចទូទៅរបស់និយោជិក ត្រូវបានចែងថា "និយោជិកត្រូវតែគោរពច្បាប់ និងស្តង់ដាការពារគ្រោះថ្នាក់ការងារដែលបានចែងក្នុងច្បាប់ ហើយអនុវត្តទៅតាមវិធានការបង្ការគ្រោះថ្នាក់ដែលដាក់ចេញដោយម្ចាស់អាជីវកម្ម និងស្ថាប័នផ្សេង" ។

## 2 ចំណុចត្រូវគោរព

ត្រូវគោរពទៅតាមវិធានការសុវត្ថិភាព និងសុខភាព
ដែលបានចេញដោយម្ចាស់អាជីវកម្ម ។

## 3 កាតព្វកិច្ចផ្សេងៗ

- និយោជិកត្រូវតែខិតខំអនុវត្តទៅតាមគោលបំណង និងការសម្រេចចិត្តរបស់គណៈកម្មការសុវត្ថិភាពនិងសុខភាពការងារ ។
- និយោជិកដែលជាអ្នកនៅក្រោមកុងត្រា ត្រូវគោរពទៅតាមវិធានការរបស់ម្ចាស់កុងត្រា ។
- ត្រូវទទួលការពិនិត្យសុខភាពដែលផ្តល់ដោយម្ចាស់អាជីវកម្ម ។
- ត្រូវតែសហការឲ្យបានល្អ ក្នុងការស្វែងរកប្រភពជម្ងឺ
- ត្រូវគោរពទៅតាមមាតិកានៃរបាយការណ៍សុវត្ថិភាពការងារ ។ និងគម្រោងលើកកម្ពស់សុវត្ថិភាពនិងសុខភាព ។
- ត្រូវតែគោរពតាមបទបញ្ញត្តិគ្រប់គ្រងសុវត្ថិភាពនិងសុខភាព ។
- គោរពទៅតាមវិធានការការពារនិយោជិក

  ប្រសិនបើនិយោជិកមានបំណងផ្អាកវិធានការគ្រប់គ្រងការការពារនិយោជិក គេត្រូវស្វែងរកការអនុញ្ញាតនិយោជក។ បើសិនជាមូលហេតុនៃការផ្អាកវិធានការលែងមាន ត្រូវចាប់ផ្តើមអនុវត្តវិធានការឡើងវិញភ្លាមដោយមិនបង្អង់។ និយោជិកត្រូវរាយការណ៍ភ្លាមទៅឱ្យនិយោជក ប្រសិនបើវិធានការការការពារលែងដំណើរការ។

# 정부의 책무

**근로자의 생명과 재산을 보호하기 위하여 정부가 하여야 할 책무는 다음과 같다.**

- 산업안전보건 정책의 수립, 집행, 조정 및 통제
- 사업장에 대한 재해 예방 지원 및 지도
- 유해하거나 위험한 기계, 기구, 설비 및 방호장치(防護裝置), 보호구(保護具) 등의 안전성 평가 및 개선
- 유해하거나 위험한 기계, 기구, 설비 및 물질 등에 대한 안전보건상의 조치기준 작성 및 지도・감독
- 사업장의 자율적인 안전보건 경영체제 확립을 위한 지원
- 안전보건의식을 북돋우기 위한 홍보, 교육 및 무재해운동 등 안전 문화 추진
- 안전보건을 위한 기술의 연구개발 및 시설의 설치・운영
- 산업재해에 관한 조사 및 통계의 유지・관리
- 안전보건 관련 단체 등에 대한 지원 및 지도・감독
- 그 밖에 근로자의 안전 및 건강의 보호・증진

**산업안전보건 문제의 공동 대처**

산업안전보건 문제를 사업주와 근로자에게만 맡기지 않고 정부가 적극적으로 관여하여 노・사・정 및 전문단체 등 4자가 공동 대처함으로써 법의 목적을 효율적으로 달성하기 위한 것이다



# កាតព្វកិច្ចរបស់រដ្ឋាភិបាល

ដើម្បីការពារអាយុជីវិតនិងទ្រព្យសម្បត្តិរបស់និយោជិក រដ្ឋាភិបាលមានកាតព្វកិច្ចដូចខាងក្រោម ។

- ការបង្កើត ការអនុវត្ត ការកែសម្រួល និងការត្រួតពិនិត្យនៃគោលនយោបាយសុវត្ថិភាពនិងសុខភាពការងារ
- ការទ្រទ្រង់និងការណែនាំក្នុងការបង្ការគ្រោះកន្លែងការងារ
- ការវាយតម្លៃនិងការធ្វើឱ្យប្រសើរឡើងនៃសុវត្ថិភាពគ្រឿងម៉ាស៊ីន, ឧបករណ៍, បរិក្ខារ និងអង្គធាតុ ដែលមានគ្រោះថ្នាក់
- ការណែនាំ ការអភិវឌ្ឍនិងការត្រួតពិនិត្យនៃវិធានការសុវត្ថិភាពនិងការគ្រប់គ្រងសុខភាពចំពោះគ្រឿងម៉ាស៊ីន, ឧបករណ៍, បរិក្ខារ និងអង្គធាតុ ដែលមានគ្រោះថ្នាក់
- ការគាំទ្រស្វ័យអនុវត្តន៍ នៃប្រព័ន្ធសុវត្ថិភាពនិងការគ្រប់គ្រងសុខភាពនៃនៅក្នុងកន្លែងការងារ
- ការលើកកម្ពស់នៃវប្បធម៌សុវត្ថិភាពដូចជាយុទ្ធនាការផ្សព្វផ្សាយ ការអប់រំ យុទ្ធនាការគ្មានគ្រោះថ្នាក់ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពនិងសុខភាព
- ការប្រមូលព័ត៌មាន និងរក្សាស្ថិតិនៃគ្រោះថ្នាក់ក្នុងការងារ
- ការគាំទ្រការណែនាំនិងការត្រួតពិនិត្យសម្រាប់អង្គការដែលទាក់ទងទៅនឹងសុវត្ថិភាពនិងសុខភាព
- ការការពារនិងការលើកកម្ពស់ផ្សេងទៀត ដើម្បីសុវត្ថិភាពនិងសុខភាពរបស់និយោជិក

### ការដោះស្រាយរួមគ្នាអំពីបញ្ហាសុវត្ថិភាពនិងសុខភាពក្នុងការងារ

រដ្ឋាភិបាលមិនទម្លាក់បន្ទុកបញ្ហាសុវត្ថិភាពនិងសុខភាពក្នុងការងារទាំងស្រុងឡើយ ។ រដ្ឋាភិបាលបានចូលរួមក្នុងការដោះស្រាយបញ្ហាពលកម្ម ឧស្សាហកម្ម យ៉ាងសកម្មជាមួយនឹងអង្គការជំនាញ ។ តាមរយៈសកម្មភាពនេះរដ្ឋាភិបាលអាចសម្រេចគោលបំណងនៃច្បាប់ ។



## 감독상의 조치

산업안전보건법령의 실효성 확보를 위해 근로감독관의 권한, 사용 중지 등 각종 명령, 관계 행정기관에의 제재 요청 등에 대하여 상세히 규정하고 있다.

### 1 근로감독관의 권한

사업장 및 지도사 사무소 등 관련 사무소에 출입하여 관계자에게 질문하고 장부, 서류, 그 밖의 물건의 검사 및 안전보건 점검을 하며, 검사에 필요한 한도 내에서 무상으로 제품, 원재료 또는 기구를 수거할 수 있다.

- 산업재해가 발생하거나 산업재해 발생의 급박한 위험이 있는 경우
- 근로자의 신고 또는 고소, 고발 등에 대한 조사가 필요한 경우
- 법 또는 법에 따른 명령을 위반한 범죄의 수사 등 사법경찰관리의 직무를 수행하기 위하여 필요한 경우
- 그 밖에 고용노동부 장관 또는 지방고용노동관서의 장이 법 또는 법에 따른 명령의 위반 여부를 조사하기 위하여 필요하다고 인정하는 경우

### 2 사용 중지

지방고용노동관서의 장은 필요하다고 인정할 때에는 사업주에게 건설물 또는 그 부속 건설물, 기계, 기구, 설비, 원재료의 대체, 사용 중지, 제거 또는 시설의 개선, 그 밖에 안전보건상의 조치를 하도록 명할 수 있다.

### 3 작업 중지

지방고용노동관서의 장은 산업재해가 발생할 급박한 위험이 있을 때 또는 명령이 지켜지지 아니하거나 위험 상태가 해제 또는 개선되지 아니하였다고 판단될 때에는 해당 기계, 설비와 관련된 작업의 전부 또는 일부를 중지할 것을 명할 수 있다.

## វិធានការសម្រាប់ការពិនិត្យ

ដើម្បីពង្រឹងប្រសិទ្ធភាពនៃច្បាប់សុវត្ថិភាពនិងសុខភាពក្នុងការងារ វិធានការគ្រប់គ្រងបានចែងច្បាប់អំពីអាជ្ញាធរនៃមន្ត្រីត្រួតពិនិត្យពលកម្ម បទបញ្ជា និងការហាមឃាត់ផ្សេងៗនៃការប្រើប្រាស់ និងការស្នើសុំការព្យាបាល ។

### 1 អាជ្ញាធរនៃមន្ត្រីត្រួតពិនិត្យពលកម្ម

មន្ត្រីត្រួតពិនិត្យសុវត្ថិភាពការងារ ទៅកាន់កន្លែងការងារ និងការិយាល័យដែលពាក់ព័ន្ធ ដូចជា ការិយាយល័យអ្នកណែនាំ ធ្វើការសាកសួរទៅកាន់ម្ចាស់អាជីវកម្ម ធ្វើការអង្កេតលើសៀវភៅធំ ឯកសារ និងរបស់ផ្សេងទៀត ហើយធ្វើការពិនិត្យសុវត្ថិភាពនិងសុខភាព។ មន្ត្រីត្រួតពិនិត្យអាចយកផលិតផលវត្ថុធាតុដើម ឬឧបករណ៍ក្នុងបរិមាណដែលចាំបាច់សម្រាប់ការពិនិត្យដោយមិនបង់ប្រាក់ ។

- បើសិនជាមានគ្រោះថ្នាក់ការងារ ឬមានកត្តាហានិភ័យគ្រោះថ្នាក់ការងារ
- បើសិនត្រូវការការអង្កេត សម្រាប់ការរាយការណ៍ ឬបណ្តឹងពីនិយោជិក
- បើសិនជាវាចាំបាច់ក្នុងការអនុវត្តកាតព្វកិច្ចរបស់ការគ្រប់គ្រង់ប៉ូលីសមានសមត្ថកិច្ច ដូចជាការសើបអង្កេតទាក់ទងនឹងការល្មើសច្បាប់ ។
- បើសិនជារដ្ឋមន្ត្រីនៃក្រសួងការងារនិងពលកម្ម ឬក៏ប្រធានការិយាល័យការងារនិងពលកម្ម ត្រូវសើបអង្កេតលើភាពល្មើសច្បាប់ ឬបញ្ញត្តិច្បាប់ ។

### 2 ការបញ្ឈប់ការប្រើប្រាស់

នៅពេលប្រធានការិយាល័យការងារនិងពលកម្មក្នុងតំបន់ គិតថាចាំបាច់ ឬទទួលស្គាល់ អាចបញ្ជាឲ្យម្ចាស់អាជីវកម្មធ្វើការផ្លាស់ប្តូរ បញ្ឈប់ការប្រើប្រាស់ លុបបំបាត់ ឬកែលម្អ ទៅលើអគារ ម៉ាស៊ីន ឧបករណ៍ បរិក្ខារ វត្ថុធាតុដើម និងវិធានការផ្សេងទៀត ដើម្បីសុវត្ថិភាពនិងសុខភាព ។

### 3 ការបញ្ឈប់ការងារ

ប្រធានការិយាល័យការងារនិងពលកម្មក្នុងតំបន់ អាចបញ្ជាឲ្យបញ្ឈប់ការងារដោយផ្នែក ឬទាំងស្រុងទាក់ទងនឹង ម៉ាស៊ីន បរិក្ខារ កិច្ចការដែលពាក់ព័ន្ធ នៅពេលដែលភាពគ្រោះថ្នាក់ការងារអាចនឹងកើតមាន ឬនៅពេលវាយតម្លៃថាបទបញ្ជាមិនត្រូវបានអនុវត្ត ឬភាពគ្រោះថ្នាក់មិនត្រូវបានបំបាត់ ឬកែលម្អ ។



## 4 관계 기관의 제재 요청 등

고용노동부 장관은 다음의 어느 하나에 해당하는 경우 행정기관의 장 또는 공공기관의 장에게 영업 정지나 그 밖의 제재를 가할 것을 요청할 수 있다.

- 법을 위반하여 많은 근로자가 사망하는 재해
- 사업장 인근 지역에 중대한 피해를 주는 등의 사고로 동시에 2명 이상의 근로자가 사망하는 재해
- 중대 산업사고의 경우
- 명령을 위반함에 따라 근로자가 업무로 인하여 사망한 경우

## 5 안전보건공단 직원의 사업장 출입 등

안전보건공단에 위탁된 권한을 행사하기 위하여 필요하다고 인정할 때에는

- 안전보건공단 소속 직원으로 하여금 사업장에 출입하여 산업재해 예방에 필요한 검사 및 지도 등을 행하게 하거나
- 역학조사를 위하여 필요한 경우 관계자에게 질문하거나 필요한 서류의 제출을 요구할 수 있다



**4 ការស្នើសុំពីស្ថាប័នពាក់ព័ន្ធ**

រដ្ឋមន្ត្រីនៃក្រសួងការងារនិងពលករ ស្នើឲ្យនាយកស្ថាប័នរដ្ឋបាល ឬនាយកស្ថាប័នសាធារណៈ ឲ្យ បិទអាជីវកម្ម ឬដាក់ទណ្ឌកម្មបន្ថែមផ្សេងៗទៀត ក្នុងករណីមានករណីណាមួយដូចខាងក្រោម ។

- គ្រោះថ្នាក់ដែលធ្វើឲ្យនិយោជិកជាច្រើនស្លាប់ ដោយសារតែល្មើសច្បាប់
- ករណីតំបន់នៅជិតកន្លែងការងារទទួលផលប៉ះពាល់ខ្លាំង ហើយមាននិយោជិកលើសពីពីរនាក់ស្លាប់ក្នុងឧបទ្ទវហេតុ
- ករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរ
- ករណីដែលនិយោជិកស្លាប់ក្នុងពេលបំពេញការងារ ដោយសារការមិនគោរពច្បាប់

**5 ការចេញចូលកន្លែងការងាររបស់បុគ្គលិកនៃសារជីវកម្មសាធារណៈ ដើម្បីសុវត្ថិភាព និងសុខភាព**

នៅពេលដែលទទួលស្គាល់ថាចាំបាច់ដើម្បីអនុវត្តអាជ្ញាសឹក ដែលបានផ្តល់ដល់សារជីវកម្មសាធារណៈដើម្បីសុវត្ថិភាពនិងសុខភាព

- បុគ្គលិកនៃសារជីវកម្មសាធារណៈដើម្បីសុវត្ថិភាពនិងសុខភាពអាចចូលទៅកន្លែងការងារ ដើម្បីធ្វើការពិនិត្យនិងណែនាំតម្រូវការចាំបាច់សម្រាប់ការបង្ការគ្រោះថ្នាក់ការងារ ។
- ករណីត្រូវការការសើបអង្កេតមូលហេតុ អាចសាកសួរទៅកាន់អ្នកគ្រប់គ្រង ឬស្នើសុំឲ្យប្រគល់ឯសារចាំបាច់ ។

# 03 작업장 안전보건 조치사항

- 안전조치
- 보건조치
- 작업 중지
- 안전보건 표지



# 03 វិធានការសម្រាប់សុវត្ថិភាព និងសុខភាពនៅកន្លែងការងារ

- វិធានការសុវត្ថិភាព
- វិធានការសុខភាព
- ការផ្អាកការងារ
- សញ្ញាសុវត្ថិភាពនិងសុខភាព



# 안전조치

## 1 안전조치를 해야 할 위험요인

- 기계, 기구, 그 밖의 설비에 의한 위험
- 폭발성, 발화성, 인화성 물질 등에 의한 위험
- 전기, 열, 그 밖의 에너지에 의한 위험

## 2 작업방법 불량에 따른 위험

- 굴착, 채석, 하역, 벌목, 운송, 조작, 운반, 해체, 중량물 취급, 그 밖의 작업을 할 때 불량한 작업방법 등으로 인하여 발생하는 위험

## 3 특수한 위험이 있는 작업장소

- 근로자가 떨어질 위험이 있는 장소
- 토사, 구축물 등이 무너져내릴 우려가 있는 장소
- 물체가 떨어지거나 날아올 위험이 있는 장소
- 그 밖에 작업 시 천재지변으로 위험이 발생할 우려가 있는 장소 등

**안전조치를 해야 할 위험요인**



# វិធានការសុវត្ថិភាព

**1** កត្តាគ្រោះថ្នាក់ដែលត្រូវការវិធានការសុវត្ថិភាព

- គ្រោះថ្នាក់ដោយសារម៉ាស៊ីន ឧបករណ៍ និងបរិក្ខារផ្សេងៗ
- គ្រោះថ្នាក់ដោយសារជាតិផ្ទុះនិងឆាបឆេះ
- គ្រោះថ្នាក់ដោយសាសរអគ្គិសនី កម្ដៅ និងថាមពលផ្សេងៗ

**2** គ្រោះថ្នាក់ដោយសារដំណើរការការងារ

- គ្រោះថ្នាក់បង្កដោយដំណើរការងារមិនល្អ នៅក្នុងជីក កាតថ្ម លើកដាក់ទំនិញ ដឹកជញ្ជូន បំបែក និងធ្វើការទាក់ទងនឹងរបស់ធ្ងន់ និងកិច្ចការផ្សេងទៀត ។

**3** បរិស្ថានការងារដែលមានការប្រថុយគ្រោះ ថ្នាក់

- កន្លែងដែលងាយនឹងធ្លាក់
- កន្លែងដីឬអគារងាយនឹងរលំ
- កន្លែងងាយនឹងមានរបស់ធ្លាក់ ឬខ្ទាត
- កន្លែងដែលងាយនឹងមានគ្រោះមហន្តរាយធម្មជាតិ

## កត្តាគ្រោះថ្នាក់ដែលត្រូវការការគ្រប់គ្រង



កត្តាគ្រោះថ្នាក់បង្កដោយម៉ាស៊ីន និងឧបករណ៍ផ្សេងទៀត

កត្តាគ្រោះថ្នាក់បង្កដោយធាតុងាយផ្ទុះ និងឆាបឆេះ

គ្រោះថ្នាក់ដោយសាសរអគ្គិសនី កម្ដៅ និងថាមពលផ្សេងៗ និងឧបករណ៍ផ្សេងទៀត



## 4 주요 사고 유형별 안전조치 기준

### 떨어짐 방지 (안전보건규칙 제42조)

- 근로자가 떨어지거나 넘어질 위험이 있는 장소에서 작업하거나
- 기계, 설비, 선박블록 등에서 작업을 할 때에 근로자가 위험해질 우려가 있는 경우 비계를 조립하는 등의 방법으로 작업발판을 설치하되, 이것이 곤란하다면 안전방망을 설치하거나 안전대를 착용하도록 하여야 한다

### 낙하물에 의한 위험의 방지 (안전보건규칙 제14조)

- 작업장의 바닥, 도로 및 통로 등에서 낙하물이 근로자에게 위험을 미칠 우려가 있는 경우 보호망을 설치하는 등 필요한 조치를 하여야 한다
- 작업으로 말미암아 물체가 떨어지거나 날아올 위험이 있는 경우 낙하물 방지망, 수직보호망 또는 방호선반의 설치, 출입금지구역의 설정, 보호구의 착용 등 위험을 방지하기 위하여 필요한 조치를 하여야 한다

### 무너짐, 떨어짐에 의한 위험 방지 (안전보건규칙 제50조)

- 지반의 무너짐, 구축물의 무너짐 또는 토석의 떨어짐 등에 의하여 근로자가 위험해질 우려가 있는 경우 그 위험을 방지하기 위하여 필요한 조치를 하여야 한다



## 4 ស្តង់ដាសម្រាប់វិធានការសុវត្ថិភាព ទៅតាមប្រភេទគ្រោះថ្នាក់

### ការបង្ការការធ្លាក់ [មាត្រាទី ១៩ នៃច្បាប់សុវត្ថិភាពនិងសុខភាព]

- បើសិននិយោជិកធ្វើការនៅកន្លែងដែលងាយធ្លាក់
- បើសិនជានិយោជិកធ្វើការជាមួយនឹងម៉ាស៊ីន ឧបករណ៍ ឬប្លុកនៃនាវា ដែលមានគ្រោះថ្នាក់ ទម្រជាន់សម្រាប់ធ្វើការងារគួរតែត្រូវបង្កើត ។ បើមិនអាចទៅរួច  សំណាញ់សុវត្ថិភាព ឬខ្សែក្រវ៉ាតសុវត្ថិភាពគួរតែត្រូវបានប្រើ ។

### កការបង្ការរបស់ធ្លាក់លើ [មាត្រាទី ១៩ នៃច្បាប់សុវត្ថិភាពនិងសុខភាព]

- បើសិនជាអាចមានគ្រោះថ្នាក់ដោយសារថ្មធ្លាក់លើអ្នកធ្វើការនៅខាងក្រោម នៅលើផ្លូវ និងផ្លូវនៃការងារ សំណាញសុវត្ថិភាពគួរតែត្រូវបានដាក់ ។
- បើសិនជាមានគ្រោះថ្នាក់ដោយសាររបស់ធ្លាក់ឬហោះ វាជាការចាំបាច់ក្នុងដាក់សំណាញ់សុវត្ថិភាព សំណាញសុវត្ថិភាពបញ្ឈរ និងបន្ទះដែទម្រ កំណត់តំបន់ហាមឃាត់ និងតំរូវឲ្យពាក់ឧបករណ៍សុវត្ថិភាព ។

### ការបង្ការរបស់ធ្លាក់លើ [មាត្រាទី ៥០ នៃច្បាប់សុវត្ថិភាពនិងសុខភាព]

- បើជាអាចមានគ្រោះថ្នាក់នៃការបាក់ដី បាក់រលំអគារ ឬធ្លាក់ថ្ម វិធានការសមរម្យគួរតែអនុវត្តដើម្បីបង្ការ ។

# 보건조치



## 1 보건조치를 해야 할 건강 장해요인

- 원재료, 가스, 증기, 분진, 흄, 미스트, 산소 결핍, 병원체 등
- 방사선, 유해광선, 고온, 저온, 초음파, 소음, 진동, 이상기압 등
- 사업장에서 배출되는 기체, 액체 또는 찌꺼기 등
- 계측 감시, 컴퓨터 단말기 조작, 정밀공작 등의 작업
- 단순 반복작업 또는 인체에 과도한 부담을 주는 작업
- 환기, 채광, 조명, 보온, 방습, 청결 등

## 2 유해인자별 보건조치

- 유기화합물 등 관리 대상 유해물질
- 백석면 등 허가 대상 유해물질 및 석면
- 청석면 등 금지 유해물질
- 사무실 오염물질
- 근골격계 부담 작업
- 그 밖의 유해인자
- 소음 및 진동
- 이상기압
- 온도, 습도
- 방사선
- 병원체
- 분진
- 밀폐공간작업

# វិធានការសុខភាព



## 1 កត្តាគ្រោះថ្នាក់សុខភាពដែលតម្រូវឲ្យមានវិធានការសុខភាព

- វត្ថុធាតុដើម ឧស្ម័ន ចំហាយ ធូលី, ផ្សែង ភាគល្អិត កង្វះអុកស៊ីសែន ធាតុបង្កជំងឺ
- ជាតិវិទ្យុសកម្ម កាំរស្មីគ្រោះថ្នាក់ សីតុណ្ហាភាពខ្ពស់ សីតុណ្ហាភាពទាប រលកសម្លេងអុលត្រា សំម្លេង រំញ័រ សម្ពាធបរិយាកាសមិនប្រក្រតី
- ឧស្ម័ន រាវ ឬ កាកសំណល់បង្ហូរចេញដោយអាជីវកម្មមួយ
- វិធានការ និងការត្រួតពិនិត្យ ការត្រួតពិនិត្យនៃស្ថានីយកុំព្យូទ័រ និងដំណើរការភាពជាក់លាក់
- ការងារដដែលៗធម្មតា ឬការងារដែលផ្តល់ស្រ្តេសខ្លាំងដល់ខ្លួនមនុស្ស
- ការប្តូរខ្យល់ ពន្លឺធម្មជាតិ ពន្លឺ អ៊ីសូឡង់កំដៅ ការពារសើម, អនាម័យ

## 2 វិធានការសុខភាពទៅតាមកត្តាគ្រោះថ្នាក់

- តម្រូវឲ្យមានការគ្រប់គ្រងសារធាតុពុល ដូចជាសារធាតុសរីរាង្គ
- សារធាតុពុលដែលតម្រូវឲ្យការអនុញ្ញាត ដូចជាភាគល្អិតសរសៃ
- សារធាតុពុលដែលហាមឃាត់ ដូចជាភាគល្អិតសរសៃពណ៌ខៀវ
- សារធាតុពុលរបស់ការិយាល័យ
- ការងារធ្វើឲ្យស្រ្តេសដល់រាងកាយ
- កត្តាគ្រោះថ្នាក់ផ្សេងៗ
- សម្លេងនិងរំញ័រ
- សម្ពាតធខុសពីធម្មតា
- សីតុណ្ហាភាព និងសំណើម
- ជាតិវិទ្យុសកម្ម
- ធាតុបង្កជម្ងឺ
- ធូលី
- ធ្វើការនៅក្នុងកន្លែងបិទជិត

# 작업 중지



## 1 사업주의 작업 중지 의무

- 산업재해 발생의 급박한 위험이 있거나
- 중대 재해가 발생한 때에는 즉시 그 작업을 중지시키고 근로자를 작업 장소로부터 대피시키는 등 안전보건상의 조치를 취할 의무가 있다

## 2 근로자의 대피권

- 사업주가 작업 중지 조치를 하지 않은 경우 근로자는 스스로 작업을 중지하고 대피할 권한을 갖는다
- 작업을 중지하고 대피하였을 때에는 지체 없이 바로 위 상급자에게 보고하여야 한다

## 3 감독기관에 대한 신고

법에 부여된 조치 의무를 사업장에서 충실히 이행하고 있는지 여부에 대한 감독은 정부의 능력만으로는 불충분하다. 그러므로 유해 · 위험요소를 직접 접하고 있는 생산 현장의 근로자가 위법사항을 신고하도록 함으로써 감독자로서의 역할을 수행하도록 하는 제도적 장치이다. 사업주는 신고를 이유로 해당 근로자에 대하여 해고나 그 밖의 불리한 처우를 하지 못한다.

# ការផ្អាកការងារ



## 1 កាតព្វកិច្ចរបស់និយោជកក្នុងការបញ្ឈប់ការងារ

- បើសិនជាអាចមានគ្រោះថ្នាក់ការងារ ឬ
- បើសិនជាមានគ្រោះថ្នាក់កើតឡើង និយោជកត្រូវតែចាត់វិធានការសុវត្ថិភាពនិងសុខភាព ដូចជាការបញ្ឈប់ការងារ និងជម្លៀសអ្នកធ្វើការ ។

## 2 សិទ្ធិភៀសខ្លួនរបស់និយោជិក

- បើសិននិយោជកមិនបញ្ឈប់ការងារ និយោជិកមានសិទ្ធិក្នុងការឈប់ធ្វើការ និងភៀសខ្លួន ។
- បើសិនជានិយោជិកបានឈប់ធ្វើការ និងភៀសខ្លួន និយោជិកត្រូវតែរាយការណ៍ទៅអ្នកគ្រប់គ្រងភ្លាមៗ ។

## 3 រាយការណ៍ទៅស្ថាប័នត្រួតពិនិត្យ

រដ្ឋាភិបាលមិនអាចត្រួតពិនិត្យអាជីវកម្ម ដើម្បីកំណត់ថាម្ចាស់អាជីវកម្មបានបំពេញតាមកាតព្វកិច្ចឬទេ ។ ដូចនេះប្រព័ន្ធមានគោលបំណងឲ្យអ្នកធ្វើការនៅទីកន្លែងផ្ទាល់ជាមួយនឹងកត្តាគ្រោះថ្នាក់រាយការណ៍ភាពល្មើសច្បាប់មកកាន់អ្នកត្រួតពិនិត្យ ។ និយោជកមិនអាចបណ្តេញឬផ្តល់ភាពមិនស្មើគ្នា
ដល់អ្នកធ្វើការដែលបានរាយការណ៍ឡើយ ។

# 안전보건 표지



사업장의 유해하거나 위험한 시설 및 장소에 대한 경고, 비상시 조치에 대한 안내, 그 밖에 안전의식 고취를 위하여 안전보건 표지를 근로자가 쉽게 알아볼 수 있는 장소, 시설 또는 물체에 설치하거나 부착하여야 한다. 외국인 근로자를 채용한 사업주는 외국어로 된 안전보건 표지와 작업안전 수칙을 부착하도록 노력하여야 한다.

## 1 안전보건 표지의 설치기준

- 근로자가 쉽게 식별할 수 있는 장소, 시설 또는 물체에 설치, 부착하여야 한다
- 흔들리거나 쉽게 파손되지 않도록 견고하게 설치, 부착하여야 한다
- 안전보건 표지의 성질상 설치 또는 부착이 곤란할 경우에는 그 물체에 직접 도장할 수 있다

# សញ្ញាសុវត្ថិភាពនិងសុខភាព



និយោជកត្រូវតែដំឡើងសញ្ញាសុវត្ថិភាពនិងសុខភាព នៅច្រើនកន្លែង បរិក្ខារ ឬវត្ថុដែលអ្នកធ្វើការងាយមើលឃើញ ដើម្បីផ្តល់ការព្រមានអំពីកត្តាគ្រោះថ្នាក់ ។ និយោជកត្រូវតែផ្តល់ការអប់រំអំពីភាពអាសន្ន និងបង្កើនការយល់អំពីសុវត្ថិភាពដល់អ្នកធ្វើការ ។ និយោជក ដែលបានជួលបុគ្គលិកបរទេស ត្រូវតែមានសញ្ញា និងការណែនាំអំពីសុវត្ថិភាពនិងសុខភាពជាភាសាដើមរបស់ជនបរទេស ។

## 1 ស្តង់ដាសម្រាប់ការដំឡើងសញ្ញាសុវត្ថិភាពនិងសុខភាព

- សញ្ញាសុវត្ថិភាពនិសុខភាពត្រូវដំឡើងនៅកន្លែង បរិក្ខារ ឬវត្ថុដែលងាយមើលឃើញដោយអ្នកធ្វើការងារ ។
- សញ្ញាសុវត្ថិភាពនិសុខភាពត្រូវដំឡើងឲ្យល្អមិនងាយខូច ឬបំលាស់ទីបាន
- បើសិនសញ្ញាសុវត្ថិភាពនិសុខភាពមិនអាចបិទឬដំឡើងបានដោយសារធម្មជាតិរបស់វា ត្រូវលាបលើវត្ថុ ។

## 2 안전보건 표지의 제작기준

- 안전보건 표지는 그 표시 내용을 근로자가 빠르고 쉽게 알아볼 수 있는 크기로 제작하여야 한다

- **작업자와 10m 떨어진 곳에 표시판을 설치하는 경우 모형의 크기는?**
  - 금지 표지 바깥지름의 크기는 d = > 0.025L ⇨ 25㎝보다 크게
  - 경고 표지(△형) 한 면의 크기는 a = >0.034L ⇨ 34㎝보다 크게
  - 경고 표지(◇형) 한 면의 크기는 a = >0.025L ⇨ 25㎝보다 크게
  - 지시 표시 바깥지름의 크기는 d = >0.025L ⇨ 25㎝보다 크게




- 안전보건 표지 속의 그림 또는 부호의 크기는 안전보건 표지 크기와 비례하여야 하며, 안전보건 표지 전체규격의 30% 이상이어야 한다
- 야간에 필요한 안전보건 표지는 야광물질을 사용하는 등 쉽게 알아볼 수 있도록 제작하여야 한다

## 2 ស្តង់ដាសម្រាប់ការផលិតសញ្ញាសុវត្ថិភាពនិងសុខភាព

- សញ្ញាសុវត្ថិភាពនិងសុខភាពត្រូវតែផលិតនៅក្នុងទំហំដែលអាចឲ្យអ្នកធ្វើការមើលបានស្រួលនិងរហ័ស

- តើសញ្ញាត្រូវមានទំហំប៉ុណ្ណា បើសិនវាត្រូវស្ថិតនៅចម្ងាយ ១០ម៉ែត្រពីអ្នកធ្វើការ?
  - អង្កត់ផ្ចិតខាងក្រៅនៃសញ្ញាហាមឃាត់៖ d = > 0.025L ⇨ វែងជាង 25cm
  - ជ្រុងនៃសញ្ញាព្រមាន (រាង ∆): a = >0.034L ⇨ វែងជាង 34cm
  - ជ្រុងនៃសញ្ញាព្រមាន (រាង ◇): a = >0.025L ⇨ វែងជាង 25cm
  - អង្កត់ផ្ចិតខាងក្រៅនៃសញ្ញាណែនាំ៖ d = >0.025L ⇨ វែងជាង 25cm




- ទំហំនៃរូបភាព ឬសញ្ញា នៅលើសញ្ញាសុវត្ថិភាពនិងសុខភាព ត្រូវតែសមាមាត្រនឹងទំហំនៃសញ្ញា ហើយត្រូវតែមានទំហំយ៉ាងតិច ៣០%នៃទំហំទាំងមូល

- សញ្ញាសុវត្ថិភាព និងសុខភាពដែលត្រូវប្រើប្រាស់ពេលយប់ ត្រូវតែអាចមើលឃើញនៅពេលយប់ ។ [លាបថ្នាំជះពន្លឺ]

## 3 사업주 및 근로자 준수사항

- 작업장 내 설치장소의 조건이나 상태에 따라 규정에 맞게 적정하게 제작, 설치 및 사용하여야 한다
- 임의로 산업안전보건 표지를 보이지 않게 가리거나 제거해서는 안 된다
- 산업안전보건 표지는 근로자가 용이하게 식별할 수 있도록 눈에 잘 띄는 위치에 설치해야 한다
- 부착된 산업안전보건 표지에 항상 관심과 주의를 기울여야 한다
- 안전보건 표지 내용 준수를 생활화하도록 하며 필요한 사항은 교육을 실시하여야 한다
- 주기적으로 안전보건 표지의 설치 상태 및 변형 유무 등을 점검한다
- 유해 · 위험요인이 변경된 작업장의 경우에는 그에 적절한 안전보건 표지로 교체해 설치한다



## 3 កាតព្វកិច្ចសម្រាប់ម្ចាស់អាជីវកម្ម និងអ្នកធ្វើការ

- សញ្ញាសុវត្ថិភាពនិងសុខភាពត្រូវបានបង្កើត ដំឡើងត្រឹមត្រូវនិងប្រើប្រាស់ដោយយោងតាមលក្ខខណ្ឌនៃទីកន្លែងនៃការដំឡើងនិងស្តង់ដានេះ។
- សញ្ញាសុវត្ថិភាពនិងសុខភាពនឹងមិនត្រូវបានគ្របដណ្តប់បានយកចេញឬតាមទំនើងចិត្ត។
- សញ្ញាសុវត្ថិភាពនិងសុខភាពត្រូវបានដំឡើងនៅក្នុងកន្លែងដែលជាកន្លែងដែលអ្នកធ្វើការអាចមើលឃើញយ៉ាងងាយស្រួល ។
- សញ្ញាសុវត្ថិភាពនិងសុខភាពដែលបានដំឡើងនឹងត្រូវបានគ្រប់គ្រងដោយការយកចិត្តទុកដាក់។
- ការណែនាំនៅលើសញ្ញាសុវត្ថិភាពនិងសុខភាពត្រូវអនុវត្តទៅតាមជារៀងរាល់ថ្ងៃ ហើយការអប់រំគួរត្រូវបានផ្តល់ជូនប្រសិនបើចាំបាច់។
- ស្ថានភាពនៃការដំឡើងនិងការខូចទ្រង់ទ្រាយនៃសញ្ញាសុវត្ថិភាពនិងសុខភាពគួរត្រូវត្រួតពិនិត្យជាទៀងទាត់។
- បើកត្តាគ្រោះថ្នាក់ឬហានិភ័យត្រូវបានផ្លាស់ប្តូរសញ្ញាសុវត្ថិភាពនិងសុខភាពដែលសមស្របនេះក៏ត្រូវដំឡើងដែរ។



## 4 안전보건 표지의 종류 및 설치장소

### 금지 표지

| 종류 | 용도 및 사용장소 | 사용장소(예시) |
|---|---|---|
| 출입 금지  | 출입을 통제하여야 할 장소 | 조립 · 해체작업장 입구 |
| 보행 금지  | 사람이 걸어 다녀서는 안 될 장소 | 중장비 운전 작업장소 |
| 차량 통행금지  | 제반 운반기기 및 차량의 통행을 금지시켜야 할 장소 | 집단 보행장소 |
| 사용 금지  | 수리 또는 고장 등으로 만지거나 작동을 금하여야 할 기계, 기구, 설비 | 고장난 기계 |
| 탑승 금지  | 엘리베이터 등에 타는 것이나 어떤 장소에 올라가는 것을 금지 | 고장난 엘리베이터 |
| 금연  | 담배를 피워서는 안 될 장소 | 인화물질 취급장소 |
| 화기 금지  | 화재 발생의 염려가 있는 장소로서 화기 취급을 금하는 장소 | 화학물질 취급장소 |
| 물체 이동 금지  | 움직여서는 안 될 물체를 보존하기 위하여 필요한 장소 | 절전스위치 옆 |

## 4 ប្រភេទនៃសញ្ញាសុវត្ថិភាពនិងសុខភាព និងកន្លែងដំឡើង

### សញ្ញហាមឃាត់

| ប្រភេទ | ការប្រើប្រាស់ និងកន្លែងប្រើប្រាស់ | កន្លែងប្រើប្រាស់ (ឧទាហរណ៍) |
|---|---|---|
| ហាមចូល  | កន្លែងដែលមិនអនុ ញ្ញាតឲ្យចេញចូល | មាត់ទ្វារនៃកន្លែ ងផ្តុំនិងបំបែក |
| ហាមដើរឆ្លងកាត់  | កន្លែងដែលមិនអោ យមនុស្សដើរកាត់ | កន្លែងប្រើឧបក រណ៍ធុនធ្ងន់ |
| ហាមយានយន្តឆ្លងកាត់  | កន្លែងដែលឧបករណ៍ដឹកជញ្ជូន និងឡានមិនអនុញ្ញាតឲ្យចូល | កន្លែងដែលមា នុស្សដើរច្រើន |
| ហាមប្រើប្រាស់  | ការប៉ះពាល់ឬដំណើការនៃម៉ាស៊ីន បរិក្ខារ និង ឧបករណ៍ត្រូវបានហាមមិនឲ្យប្រើប្រាស់ដោយសារការជួសជុលឬខូច | ម៉ាស៊ីនដែលខូច |
| ហាមជិះ  | ហាមឃាត់ការជិះជណ្តើរយន្តឬ ឡើងកន្លែងណាមួយ | ជណ្តើរយន្តដែលខូច |
| ហាមជក់បារី  | កន្លែងដែលមិនអនុញ្ញាតឲ្យជក់បារី | កន្លែងមានធាតុងាយឆាបឆេះ |
| ហាមប្រើភ្លើង  | កន្លែងដែលងាយមានភ្លើងឆាបឆេះ ដូចនេះមិនអនុញ្ញាតឲ្យប្រើភ្លើង | កន្លែងប្រើប្រាស់សារធាតុគីមី |
| ហាមបំលាស់ទី  | កន្លែងត្រូវការរក្សាវត្ថុដែលមិនអនុញ្ញាតឲ្យបំលាស់ទី | ក្បែរកន្លែងកុង តាក់បិទភ្លើង |

## 경고 표지

| 종류 | 용도 및 사용장소 | 사용장소(예시) |
|---|---|---|
| 인화성물질 경고 | 휘발유 저장소 등 화기의 취급을 극히 주의하여야 하는 장소 | 휘발유 저장탱크 |
| 산화성물질 경고 | 가열, 압축 및 강산 등의 첨가로 강한 산화성을 나타내는 물질 | 질산 저장탱크 |
| 폭발성물질 경고 | 폭발성의 물질이 있는 장소 | 폭발물 저장실 |
| 급성독성물질 경고 | 독극물이 있는 장소 | 농약 제조 · 보관소 |
| 부식성물질 경고 | 물체 등에 떨어짐으로써 그 물체를 부식시키는 물질이 있는 장소 | 황산 저장실 |
| 방사성물질 경고 | 방사능 물질이 있는 장소 | 방사성동위원소 사용실 |
| 고압전기 경고 | 발전소나 고압이 흐르는 장소 | 감전 우려지역 입구 |
| 매달린 물체 경고 | 머리 위에 크레인 등과 같은 달려 있는 물체가 있는 장소 | 크레인작업장 입구 |
| 낙하물 경고 | 돌, 블록 등이 떨어질 염려가 있는 장소 | 비계 설치장소 입구 |
| 고온 경고 | 고도의 열을 발하는 물체 또는 온도가 아주 높은 장소 | 주물작업장 입구 |
| 저온 경고 | 아주 차가운 물체 또는 온도가 아주 낮은 장소 | 냉동작업장 입구 |
| 몸 균형 상실 경고 | 미끄러운 장소 등 넘어지기 쉬운 장소 | 경사진 통로 입구 |
| 레이저광선 경고 | 레이저광선에 노출될 우려가 있는 장소 | 레이저실험실 입구 |
| 발암성, 변이원성, 생식독성, 전신독성, 호흡기 과민성물질 경고 | 기타 인체에 해로운 물체가 있는 장소 또는 당해물질 | 분진 발생장소 |
| 위험장소 경고 | 기타 위험한 물체가 있는 장소 또는 당해 물체 | 고열 금속찌꺼기 폐기장소 |

## សញ្ញាព្រមាន

| ប្រភេទ | ការប្រើប្រាស់ និងកន្លែងប្រើប្រាស់ | កន្លែងប្រើប្រាស់ (ឧទាហរណ៍) |
|---|---|---|
| ព្រមានៈ វត្ថុងាយឆេះ | កន្លែង ដែលភ្លើងត្រូវបានហាមឃាត់យ៉ាងតឹងរឹង ដូចជាស៊ីទែនប្រេង | ស៊ីទែនប្រេង |
| ព្រមានៈ វត្ថុងាយនឹងធ្វើអុកស៊ីតកម្ម | វត្ថុដែលមានអុកស៊ីតកម្មខ្លាំង នៅពេលត្រូវ ក្តៅ បណ្ណែន ឬអាស៊ីតខ្លាំង | ស៊ីទែនផ្ទុកអាសូត |
| ព្រមានៈវត្ថុងាយផ្ទុះ | កន្លែងដែលមានវត្ថុងាយផ្ទុះ | កន្លែងផ្ទុកវត្ថុងាយផ្ទុះ |
| ព្រមានៈវត្ថុពុលលឿន | កន្លែងដែលមានវត្ថុពុល | កន្លែងផលិតនិងផ្ទុកថ្នាំសម្លាប់សត្វល្អិត |
| ព្រមានៈ វត្ថុកាត់ | កន្លែងដែលមានអង្គធាតុ ដែលអាចកាត់ ដោយធ្លាក់លើ | កន្លែងផ្ទុកអាស៊ីតសុលផួរិច |
| ព្រមានៈ វត្ថុមានជាតិវិទ្យុសកម្ម | កន្លែងដែលមានជាតិវិទ្យុសកម្ម | កន្លែងមានអ៊ីសូតូបវិទ្យុសកម្ម ដែលត្រូវបានប្រើប្រាស់ |
| ព្រមានៈ អគ្គិសនីចរន្តខ្ពស់ | រោងចក្រអគ្គិសនី ឬកន្លែងដែលមានអគ្គិសនីចរន្តខ្ពស់ | ច្រកចូលកន្លែងដែលមានគ្រោះថ្នាក់ឆក់ខ្សែភ្លើង |
| ព្រមានៈ មានរបស់ព្យួរ | កន្លែងដែលមានរបស់ព្យួរ នៅខាងលើ ដូចជាឧបករណ៍សន្ទូច | ច្រកចូលកន្លែងដែល មានឧបករណ៍ស្ទូច |
| ព្រមានៈ របស់ធ្លាក់ | កន្លែងដែលមានថ្ម ឬវត្ថុអាចធ្លាក់ | ច្រកចូលកន្លែងដែលមានទំរធ្វើការ |
| ព្រមានៈ សីតុណ្ហាភាពខ្ពស់ | កន្លែងដែលមានវត្ថុក្តៅខ្លាំង ឬកន្លែងដែលមានសីតុណ្ហាភាពខ្ពស់ | ច្រកចូលកន្លែងចាក់ពុម្ពដែក |
| ព្រមានៈសីតុណ្ហាភាពទាប | កន្លែងដែលមានវត្ថុត្រជាក់ខ្លាំង ឬកន្លែងដែលមានសីតុណ្ហាភាពទាប | ច្រកចូលកន្លែងបង្កក |
| ព្រមានៈ រអិល | កន្លែងដែលរអិល | ច្រកចូលកន្លែងមានផ្លូវទេរ |
| ព្រមានៈ កាំរស្មីឡាស៊ែ | កន្លែងដែលមានគ្រោះថ្នាក់ដោយសារត្រូវកាំរស្មីឡាស៊ែ | ច្រកចូលនៃបន្ទប់ពិសោធន៍កាំរស្មីឡាស៊ែ |
| ព្រមានៈបង្កមហារីក ប្រភពជម្ងឺខូចប្រព័ន្ធបន្តពូជ ពុលរាងកាយ ប៉ះពាល់ដល់ប្រព័ន្ធដង្ហើម | កន្លែងដែលមានសារធាតុមិនល្អសម្រាប់មនុស្ស ឬ វត្ថុពុល | កន្លែងដែលមានធូលីច្រើន |
| ព្រមានៈ កន្លែងគ្រោះថ្នាក់ | កន្លែងដែលមានសារធាតុមិនល្អសម្រាប់មនុស្ស ឬ វត្ថុពុល | កន្លែងដែលមានកម្ទេចកំទីដែកក្តៅ |

## 지시 표지

| 종류 | 용도 및 사용장소 | 사용장소(예시) |
|---|---|---|
| 보안경 착용  | 보안경을 착용하여야만 작업 또는 출입을 할 수 있는 장소 | 그라인더 작업장 입구 |
| 방독마스크 착용  | 방독마스크를 착용하여야만 작업 또는 출입을 할 수 있는 장소 | 유해물질 작업장 입구 |
| 방진마스크 착용  | 방진마스크를 착용하여야만 작업 또는 출입을 할 수 있는 장소 | 분진이 많은 곳 |
| 보안면 착용  | 보안면을 착용하여야만 작업 또는 출입을 할 수 있는 장소 | 용접실 입구 |
| 안전모 착용  | 안전모를 착용하여야만 작업, 출입을 할 수 있는 장소 | 고소 작업장 입구 |
| 귀마개 착용  | 소음으로 귀마개를 착용하여야만 작업, 출입을 할 수 있는 장소 | 판금 작업장 입구 |
| 안전화 착용  | 안전화를 착용하여야만 작업 또는 출입을 할 수 있는 장소 | 중량물 취급 작업장 입구 |
| 안전장갑 착용  | 안전장갑을 착용하여야만 작업 또는 출입을 할 수 있는 장소 | 고온 및 저온 작업장 |
| 안전복 착용  | 방열복 등의 안전복을 착용하여야만 작업, 출입을 할 수 있는 장소 | 단조 작업장 입구 |

## សញ្ញាណែនាំ

| ប្រភេទ | ការប្រើប្រាស់ និងកន្លែងប្រើប្រាស់ | កន្លែងប្រើប្រាស់ (ឧទាហរណ៍) |
|---|---|---|
| ពាក់វ៉ែនតាសុវត្ថិភាព  | កន្លែងដែលតម្រូវឲ្យអ្នកធ្វើការពាក់វ៉ែនតាការពារទើបអាចឆ្លងកាត់ឬធ្វើការងារបាន | ច្រកចូលកន្លែងកិនរបស់ |
| ពាក់ម៉ាសការពារសារធាតុពុល  | កន្លែងដែលតម្រូវឲ្យអ្នកធ្វើការពាក់ម៉ាសការពារសារធាតុពុលទើបអាចឆ្លងកាត់ឬធ្វើការងារបាន | ច្រកចូលកន្លែងដែលមា នសារធាតុពុល |
| ពាក់ម៉ាសការពារធូលី  | កន្លែងដែលតម្រូវឲ្យអ្នកធ្វើការពាក់ម៉ាសការពារធូលីទើបអាចឆ្លងកាត់ឬធ្វើការងារបាន | កន្លែងមានធូលី |
| ពាក់របាំងមុខសុវត្ថិភាព  | កន្លែងដែលតម្រូវឲ្យអ្នកធ្វើការពាក់របាំងមុខសុវត្ថិភាពទើបអាចឆ្លងកាត់ឬធ្វើការងារបាន | ច្រកចូលកន្លែងបន្សារ |
| ពាក់មួកសុវត្ថិភាព  | កន្លែងដែលតម្រូវឲ្យអ្នកធ្វើការពាក់មួកសុវត្ថិភាពទើបអាចឆ្លងកាត់ឬធ្វើការងារបាន | ច្រកចូលកន្លែងខ្ពស់ |
| ពាក់ប្រដាប់ញាត់ត្រចៀក  | កន្លែងដែលតម្រូវឲ្យអ្នកធ្វើការពាក់ប្រដាប់ញាត់ត្រចៀកទើបអាចឆ្លងកាត់ឬធ្វើការងារបាន | ច្រកចូលកន្លែងបង្កើតបន្ទះដែក |
| ពាក់ស្បែកជើងសុវត្ថិភាព  | កន្លែងដែលតម្រូវឲ្យអ្នកធ្វើការពាក់ស្បែកជើងសុវត្ថិភាពទើបអាចឆ្លងកាត់ឬធ្វើការងារបាន | ច្រកចូលកន្លែងធ្វើការជាមួយនឹងរបស់ធ្ងន់ |
| ពាក់ពាក់ស្រោមដៃសុវត្ថិភាព  | កន្លែងដែលតម្រូវឲ្យអ្នកធ្វើការពាក់ស្រោមដៃសុវត្ថិភាពទើបអាចឆ្លងកាត់ឬធ្វើការងារបាន | កន្លែងមានសីតុណ្ហភាពទាបឬខ្ពស់ខ្លាំង |
| ពាក់សម្លៀកបំពាក់សុវត្ថិភាព  | កន្លែងដែលតម្រូវឲ្យអ្នកធ្វើការពាក់សម្លៀកបំពាក់សុវត្ថិភាពទើបអាចឆ្លងកាត់ឬធ្វើការងារបាន | ច្រកចូលកន្លែងដុតដែក |

## 안내 표지

| 종류 | 용도 및 사용장소 | 사용장소(예시) |
|---|---|---|
| 녹십자 표지  | 안전의식을 고취하기 위하여 필요한 장소 | 많은 사람들이 있는 장소 |
| 응급구호 표지  | 응급구호설비가 있는 장소 | 위생구호실 |
| 들것  | 구호를 위한 들것이 있는 장소 | - |
| 세안장치  | 세안장치가 있는 장소 | - |
| 비상용 기구   | 비상용 기구가 있는 장소 | - |
| 비상구  | 비상출입구 | - |
| 왼쪽 비상구  | 비상구가 왼쪽에 있음을 알려야 하는 장소 | - |
| 오른쪽 비상구  | 비상구가 오른쪽에 있음을 알려야 하는 장소 | - |

## សញ្ញាផ្តល់ដំណឹង

| ប្រភេទ | ការប្រើប្រាស់ និងកន្លែងប្រើប្រាស់ | កន្លែងប្រើប្រាស់ (ឧទាហរណ៍) |
|---|---|---|
| សញ្ញាបូកពណ៌បៃតង  | កន្លែងចាំបាច់ ដើម្បីបង្កើនការយល់ដឹងអំពីសុវត្ថិភាព | កន្លែងមានមនុស្សច្រើន |
| សង្គ្រោះបន្ទាន់  | កន្លែងដែលមានឧបករណ៍សង្គ្រោះបន្ទាន់ | មជ្ឈមណ្ឌលសង្គ្រោះបន្ទាន់ |
| ប្រដាប់សែង  | កន្លែងដែលមានប្រដាប់សែងក្នុងជំនួយបន្ទាន់ | - |
| ប្រដាប់លាងមុខ  | កន្លែងដែលមានប្រដាប់លាងមុខ | - |
| ឧបករណ៍ពេលអាសន្ន   | កន្លែងដែលមានឧបករណ៍ ពេលអាសន្ន | - |
| ច្រកចេញអាសន្ន  | ច្រកចេញអាសន្ន | - |
| ច្រកចេញនៅខាងឆ្វេង  | កន្លែងដែលមានច្រកចេញអាសន្ននៅខាងឆ្វេង | - |
| ច្រកចេញនៅខាងស្តាំ  | កន្លែងដែលមានច្រកចេញអាសន្ននៅខាងស្តាំ | - |

## 5 안전보건 표지의 종류와 형태

### 1. 금지 표지


101
출입 금지


102
보행 금지


103
차량통행 금지


104
사용 금지


105
탑승 금지


106
금연


107
화기 금지


108
물체 이동 금지

### 2. 경고표지


201
인화성물질 경고


202
산화성물질 경고


303
폭발성물질 경고


204
급성독성물질 경고


205
부식성물질 경고


206
방사성물질 경고


207
고압전기 경고


208
매달린 물체 경고


209
낙하물 경고


210
고온 경고


210-1
저온 경고


211
몸 균형 상실 경고


212
레이저광선 경고


213
발암성 · 변이원성 · 생식독성
· 전신독성 · 호흡기 과민성
물질 경고


214
위험장소 경고

## 5 ប្រភេទនិងរាងនៃសញ្ញាសុវត្ថិភាពនិងសុខភាព

### 1. សញ្ញាហាមឃាត់



101 ហាមចូល
102 ហាមដើរឆ្លងកាត់
103 ហាមយានយន្តឆ្លងកាត់
104 ហាមប្រើប្រាស់
105 ហាមជិះ



106 ហាមជក់បារី
107 ហាមប្រើភ្លើង
108 ហាមបំលាស់ទី

### 2. សញ្ញាព្រមាន



201 ព្រមាន៖ វត្ថុងាយឆេះ
202 ព្រមាន៖ វត្ថុងាយនឹងធ្វើអុកស៊ីតកម្ម
303 ព្រមាន៖វត្ថុងាយផ្ទុះ
204 ព្រមាន៖វត្ថុពុលលឿន
205 ព្រមាន៖វត្ថុកាត់



206 ព្រមាន៖ វត្ថុមានជាតិវិទ្យុសកម្ម
207 ព្រមាន៖ អគ្គិសនីចរន្តខ្ពស់
208 ព្រមាន៖ មានរបស់ព្យួរ
209 ព្រមាន៖ របស់ធ្លាក់
210 ព្រមាន៖ សីតុណ្ហាភាពខ្ពស់



210-1 ព្រមាន៖សីតុណ្ហាភាពទាប
211 ព្រមាន៖ រអិល
212 ព្រមាន៖ កាំរស្មីឡាស៊ែ
213 ព្រមាន៖បង្កមហារីក ប្រភពជម្ងឺ ខូចប្រព័ន្ធបន្តពូជ ពុលរាងកាយ ប៉ះពាល់ដល់ប្រព័ន្ធដង្ហើម
214 ព្រមាន៖ កន្លែងគ្រោះថ្នាក់

## 3. 지시 표지


301
보안경 착용


302
방독마스크 착용


303
방진마스크 착용


304
보안면 착용


305
안전모 착용


306
귀마개 착용


307
안전화 착용


308
안전장갑 착용


309
안전복 착용

## 4. 안내 표지


401
녹십자 표지


402
응급구호 표지


402-1
들것


402-2
세안장치


403
비상구


403-1
왼쪽 비상구


403-2
오른쪽 비상구

## 5. 문자 추가 시 범례



## 3. សញ្ញាណែនាំ


301
ពាក់វ៉ែនតាសុវត្ថិភាព


302
ពាក់ម៉ាសការពារសារធាតុពុល


303
ពាក់ម៉ាសការពារធូលី


304
ពាក់របាំងមុខសុវត្ថិភាព


305
ពាក់មួកសុវត្ថិភាព


306
ពាក់ប្រដាប់ញ្ញាត់ត្រចៀក


307
ពាក់ស្បែកជើងសុវត្ថិភាព


308
ពាក់ពាក់ស្រោមដៃសុវត្ថិភាព


309
ពាក់សម្លៀកបំពាក់សុវត្ថិភាព

## 4. សញ្ញាផ្តល់ដំណឹង


401
សញ្ញាបូកពណ៌បៃតង


402
សង្គ្រោះបន្ទាន់


402-1
ប្រដាប់សែង


402-2
ប្រដាប់លាងមុខ


403
ច្រកចេញអាសន្ន


403-1
ច្រកចេញនៅខាងឆ្វេង


403-2
ច្រកចេញនៅខាងស្តាំ

## 5. កំណត់ចំណាំពេលបន្ថែមអក្សរ



2014 – 교육미디어 –512

# 고객님의 소중한 평가를 기다립니다

- 여러분이 보내주신 소중한 의견을 반영하여 더 좋은 안전보건 자료를 만들어나가겠습니다
- 아래 설문 양식을 작성하여 팩스(052-703-0322)로 보내주시면 감사하겠습니다

**본 자료가 여러분의 재해 예방활동에 기여한다고 생각하십니까?**

○ 매우 그렇다 ○ 그렇다 ○ 보통 ○ 그렇지 않다 ○ 전혀 그렇지 않다

**귀하는 회사에서 어떤 직책을 맡고 계십니까?**

○ 경영층 ○ 안전보건 관리자 ○ 관리 감독자 ○ 근로자 ○ 기타

**본 자료가 만족스러우셨습니까?**

| | 매우 만족 | 만족 | 보통 | 불만족 | 매우 불만족 |
|---|---|---|---|---|---|
| 디자인 · 편집 | ○ | ○ | ○ | ○ | ○ |
| 내용 구성 | ○ | ○ | ○ | ○ | ○ |
| 전반적 만족도 | ○ | ○ | ○ | ○ | ○ |

**귀하께서 근무하는 회사에 대해**

업종

○ 제조업 ○ 건설업 ○ 전기·가스·수도업 ○ 운수·창고·통신업 ○ 임업·농업·어업 ○ 기타산업
○ 위생 및 유사서비스업 ○ 보건 및 사회복지사업 ○ 건물종합관리업 ○ 음식 및 숙박업 ○ 도·소매업 및 수리업 ○ 교육·임대 및 사업서비스업

규모

○ 5인 미만 ○ 5~49인 ○ 50~99인 ○ 100~299인 ○ 300인 이상

- 고객님의 인적사항을 적어주세요 (내용이 누락될 경우 추첨 대상에서 제외됩니다)

| | | | |
|---|---|---|---|
| 이름 | | 전화 | |
| 회사명 | | | |
| 회사 주소 | | | |

▣ 개인정보 수집 및 이용 안내

이용자는 해당 개인정보 수집 및 이용 동의에 대한 거부 권리가 있습니다

❶ 개인정보의 수집 · 이용 목적
안전보건 미디어 만족도 측정, 경품 추첨 및 우편 발송 등 서비스 제공에 관련한 목적으로 개인정보를 수집 · 이용

❷ 수집 · 이용 개인 정보 항목
이름, 전화번호, 회사명, 회사주소

❸ 개인정보 보유 및 이용기간
개인정보 수집 해당 연도(경과 시 일괄 폐기)

상기 내용을 읽고 개인정보 수집 · 이용에 동의합니다 ☐ (동의시 체크 표시)
개인정보 수집 · 이용에 동의하셔야 경품 증정 등 서비스가 제공될 수 있습니다

**Fax 번호:** 052-703-0322 **문의사항:** 안전보건공단 미디어개발팀 052-703-0699

산업재해예방 안전보건공단



챙기셨나요?
위기탈출
애플리케이션
사고포착
실시간 재해 정보와
대처 방안 제공
다국어회화
일터 및 일상생활에 유용한
10개 외국어 회화 제공
지식충전소
알아야 할 안전보건 정보를
검색할 수 있도록 제공
응급조치
일터 및 생활 속 응급조치에 관한
기본 지식과 대처방법 제공
바이오리듬
바이오리듬에 따른
안전건강 대처 요령 제공
월간 안전보건
'월간 안전보건'을 스마트폰으로
볼 수 있도록 제공
기초안전 보건교육
스마트폰으로 기초안전
보건교육 이수 확인
체조송
체조송과 바른 자세송
스트레칭 동영상 제공
MSDS 요약정보
불산 등 화학물질의 유해성·위험성과
응급조치 요령 제공
고용노동부
산업재해예방
안전보건공단
QR코드를 찍으면
위기탈출 애플리케이션을
다운로드할 수 있습니다.

조심조심 코리아

CAMBODIA

산업재해예방
안전보건공단
KOREA OCCUPATIONAL SAFETY & HEALTH AGENCY

400, Jongga-ro, Jung-gu, Ulsan, REPUBLIC OF KOREA
울산광역시 중구 종가로 400
TEL 052.7030.500 | 1644.4544

QR코드를 스캔하면
'다국어회화앱'을 설치하실 수 있습니다.

អ្នកអាចដំឡើងកម្មវិធី "សន្ទនាពហុភាសា"
ដោយគ្រាន់តែស្កេនQRកូដ